# ការណែនាំពីការចិញ្ចឹមពពែជាលក្ខណៈគ្រួសារនៅកម្ពុជា

# Improving Goat Raising in Cambodia



រៀបរៀងដោយៈ **បណ្ឌិត មាឃ ប្រមូល**

បោះពុម្ពដោយៈ **មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC)**

ឧបត្ថម្ភដោយៈ អង្គការ **ZOA** និង **ECHO**

# អារម្ភកថា

ការចិញ្ចឹមសត្វជាផ្នែកមួយក្នុងវិស័យកសិកម្ម នៅប្រទេសកម្ពុជាកសិករច្រើនចិញ្ចឹមជាលក្ខណៈគ្រួសារ ។

ពពែ ជាសត្វដែលមានប្រយោជន៍ច្រើនយ៉ាងដូចជា ផ្តល់សាច់ដែលមានឱជារស និងថាមពលច្រើន ផ្តល់ទឹកដោះដែលអាចកែច្នៃជាផលិតផលសំរាប់បរិភោគផ្សេងទៀត ស្បែកសំរាប់យកទៅកែច្នៃធ្វើជាសំភារៈប្រើប្រាស់ផ្សេងៗ ដូចជា ខ្សែក្រវាត់ កាបូប ស្បែកជើង ។ល។ ពពែ ក៏ផ្តល់នូវលាមកដ៏មានតំលៃសំរាប់យកទៅធ្វើជាជីដាក់ដំណាំផ្សេងៗ ( លាមករបស់ពពែសំបូរជាតិអាហារូតជាងលាមករបស់គោ ក្របី ) ។

កន្លងមកនៅប្រទេសកម្ពុជាយើង កសិករពុំសូវមានការចាប់អារម្មណ៍ក្នុងការចិញ្ចឹមពពែប៉ុន្មានទេ ព្រោះប្រជាជនពុំសូវនិយមបរិភោគសាច់ពពែ ឬទឹកដោះពពែ ។ សព្វថ្ងៃសត្វពពែមានតំលៃថ្លៃនៅលើទីផ្សារ ហើយចំនួនអ្នកចង់ចិញ្ចឹមពពែក៏ មានការកើនឡើងដែរ ។ ដើម្បីជាជំនួយដល់បងប្អូនកសិករដែលមានចំណាប់អារម្មណ៍ក្នុងការចិញ្ចឹមពពែ យើងសូមផ្តល់នូវពតិមានសំខាន់ៗ ទាក់ទងទៅនឹងការចិញ្ចឹមពពែ ជាពិសេសការជ្រើសរើសពូជ ។

សៀវភៅ "ការណែនាំពីការចិញ្ចឹមពពែជាលក្ខណៈគ្រួសារនៅកម្ពុជា " ត្រូវបានរៀបរៀងឡើងជាភាសាខ្មែរ ដោយបានបកប្រែកែសំរួលចេញពីសៀវភៅ "Goat Development Program-Sri Lanka-German Goat Development Project" និងយោងទៅលើការចុះសិក្សាផ្ទាល់ពីការចិញ្ចឹមពពែក្នុងតំបន់មួយចំនួននៅប្រទេសកម្ពុជា ។ ការចងក្រងសៀវភៅនេះ ផ្អែកលើតំរូវការរបស់អង្គការ សេដាក **CEDAC** និងអង្គការ **ZOA** សំរាប់បណ្តុះបណ្តាលបុគ្គលិក កសិករតាមតំបន់គោលដៅ និងកសិករទូទៅក្នុងប្រទេសកម្ពុជា ។ សៀវភៅនេះបង្ហាញពីបច្ចេកទេសសាមញ្ញក្នុងការចិញ្ចឹមពពែជាលក្ខណៈគ្រួសារ ដោយបង្ហាញពីការជ្រើសរើសពូជ ការផ្តល់ចំណី ការថែទាំ និងជំងឺដែលជួបប្រទះញឹកញាប់ក្នុងការចិញ្ចឹមពពែ ។ល ។

យើងខ្ញុំរីករាយរង់ចាំរាល់ការរិះគន់កែលំអក្នុងន័យស្ថាបនាពីសំណាក់ លោក លោកស្រី អ្នកបច្ចេកទេស ប្រជាកសិករ និងអ្នកពាក់ព័ន្ធដទៃទៀត ។

# មាតិកាអត្ថបទ

ទំព័រ


**១. សារៈសំខាន់ក្នុងការចិញ្ចឹមពពែ** ១

**២. ពូជ** ១

**៣. ការជ្រើសរើសពូជ និងការបន្លាត់ពូជ** ១

៣.១. ការជ្រើសរើសពពែបា ២

៣.២. ការក្រៀវពពែ ៣

៣.៣. ពពែញីទុកធ្វើពូជ ៤

៣.៤. ដំណើរការនៃការបន្តពូជ ៧

**៤. ទ្រុង** ៩

៤.១. ទ្រុងពពែដែលសង់ផ្ទាល់ដី ៩

៤.២. ទ្រុងពពែដែលសង់ផុតពីដី ១០

៤.៣. តើអ្នកត្រូវសង់ទ្រុងពពែនៅកន្លែងណា? ១២

**៥. ការថែទាំមេពពែដើម** ១៤

**៦. ការបង្កើតកូនពពែ** ១៥

៦.១. ការបង្កើតកូនធម្មតា ១៦

៦.២. ការជួយមេពពែក្នុងពេលកើតកូន ១៧

៦.៣. ការចិញ្ចឹមកូនពពែ ១៨

៦.៤. ការផ្តល់ចំណីកូនពពែដោយដប ១៩

៦.៥. តារាងនៃការផ្តល់ចំណីសំរាប់កូនពពែ ២០

**៧. ការគ្រប់គ្រង និងការផ្តល់ចំណី** ២២

៧.១. របៀបគ្រប់គ្រង៣យ៉ាង និងប្រព័ន្ធនៃការផ្តល់ចំណី ២២

៧.១.១. ប្រព័ន្ធនៃការផ្តល់ចំណីក្នុងទ្រុង ២២

៧.១.២. ប្រព័ន្ធនៃការផ្តល់ចំណីដោយចង ២៣
៧.១.៣. ប្រព័ន្ធនៃការចិញ្ចឹមលែងឱ្យស៊ីលើវាលស្មៅ ២៣
៧.១.៤. ទំលាប់របស់សត្វពពែក្នុងការស៊ីចំណី ២៤

**៨. ប្រភេទចំណី និងប្រភពចំណី** ២៥
៨.១. ការលែងឱ្យស៊ីលើវាលស្មៅ ២៥
៨.២. ការកំណត់ព្រំដែនឱ្យស៊ីលើវាលស្មៅ ២៥
៨.៣. ចំណីបៃតង ២៧
៨.៤. ចំណីដែលបានមកពីកាកសំណល់ផ្ទះបាយ ៣០
៨.៥. ចំណីដែលបានមកពីអនុផលកសិកម្ម ៣១
៨.៦. ចំណីផ្សំ ៣១
៨.៧. សារធាតុខនិជ (mineral) ៣២
៨.៨. កំឡុងពេលខ្សត់ចំណី ៣៣

**៩. ទឹក** ៣៤
**១០. ការថែទាំពពែ** ៣៥
១០.១. ការថែទាំ និងធ្វើអនាម័យ ៣៦
**១១. ជំងឺ** ៣៨
១១.១ ក្រចកពណ៌ក្រហម ៣៨
១១.២ ការថែទាំ ព្យាបាលមុខរបួសតូច និងបួស ៣៩
របួសហូរឈាម ៤០
ពស់ចឹក ៤០
១១.៣ ប៉ារ៉ាស៊ីតខាងក្រៅ ៤០
អង្កែរ ៤១
ការការពារ និងការព្យាបាលប៉ារ៉ាស៊ីតខាងក្រៅ ៤១
១១.៤ ប៉ារ៉ាស៊ីតខាងក្នុង ៤២

ការការពារ និងព្យាបាលប៉ារ៉ាស៊ីតខាងក្នុង ៤២
១១.៥ កុកស៊ីដ្យូស៊ីស (Coccidiosis) ៤៣
១១.៦ ជំងឺខ្វិន (goat paralysis) ៤៤
១១.៧ ជំងឺសួត (pneumonia) ៤៥
១១.៨ ជំងឺរលាកស្បែក (Contagious Pustular Dermatitis) ៤៧
១១.៩ ជំងឺហើមពោះ (Bloat) ៤៧
១១.១០ រោគរលាកដោះ (mastitis) ៤៨
១១.១១ ជំងឺអុតក្តាម ៤៩
១១.១២ ជំងឺសារទឹក ៥០
១១.១៣ ជំងឺបុស្តខ្យល់ ៥១

## តារាង

**ទំព័រ**

តារាងទី ១: តម្រូវការផ្ទៃក្រឡាទ្រុងសំរាប់ពពែ ១ក្បាល ១២

តារាងទី ២: តារាងនៃការផ្តល់ចំណី - ការផ្តល់ចំណីដោយជបជល់កូនពពែ ២១

តារាងទី ៣: ជំងឺសំខាន់ៗ ៥២

## រូបភាព

រូបទី ១: ពូជពពែដែលកសិករចិញ្ចឹមក្នុងស្រុក ១
រូបទី ២: កូនពពែ និងមេដែលមានសុខភាពល្អ និងមាំមួន ២
រូបទី ៣: ពពែបាសំរាប់ធ្វើពូជ ៣
រូបទី ៤: ឧបករណ៍សំរាប់ក្រៀវពពែ
(Burdizzo និង Elastrator Rubber Rings) ៤
រូបទី ៥: ពពែញីដែលល្អសំរាប់ទុកពូជ ៥
រូបទី ៦: មេពពែដែលមានកន្សោមដោះមិនល្អ (កន្សោមដោះយារ) ៦
រូបទី ៧: កន្សោមដោះមិនល្អ ៦
រូបទី ៨: មេពពែដែលមានកន្សោមដោះល្អ ៦
រូបទី ៩: ទំរង់ជើងមិនល្អ ៧
រូបទី ១០: ទ្រុងពពែដែលសង់ផ្ទាល់ដី ១០
រូបទី ១១: ទ្រុងពពែសង់ផុតពីដី ១១
រូបទី ១២: ធ្នើរ ឬទ្រុងសំរាប់ដាក់ស្មៅ ដោយភ្ជាប់ទៅនឹងជញ្ជាំង ១៣
រូបទី ១៣: ការថែទាំមេពពែដើម ១៥
រូបទី ១៤: ការកាត់សំអាតរោមខាងក្រោយរបស់មេពពែមុនកើតកូន ១៦
រូបទី ១៥: ទ្រុងសំរាប់កូនពពែដែលទើបកើត ១៧
រូបទី ១៦: ការជួយមេពពែក្នុងពេលកើតកូន ១៨

រូបទី ១៧: កូនពពែក្នុងពេលបៅដោះ ១៩
រូបទី ១៨: ការលែងពពែឱ្យស៊ីលើវាលស្មៅ និងតាមគម្ពោធព្រៃ ២៤
រូបទី ១៩: ការកំណត់ចងពពែឱ្យស៊ីលើវាលស្មៅ ២៦
រូបទី ២០: ស្លឹក និងដើមកន្ទំថេតសំរាប់ជាចំណីពពែ ២៨
រូបទី ២១: ស្លឹកដំឡូងមីជាចំណីពពែ ២៩
រូបទី ២២: ការបោសសំអាតទ្រុងប្រចាំថ្ងៃ ៣៧

## ១. សារៈសំខាន់ក្នុងការចិញ្ចឹមពពែ

ការចិញ្ចឹមពពែផ្តល់ផលប្រយោជន៍ច្រើនយ៉ាងៈ

- ផ្តល់សាច់ដែលមានឱជារស និងថាមពលច្រើន
- ផ្តល់ទឹកដោះ ដែលអាចកែច្នៃជាផលិតផលសំរាប់បរិភោគផ្សេងទៀត
- ស្បែករបស់ពពែសំរាប់យកទៅកែច្នៃធ្វើជាសំភារៈប្រើប្រាស់ផ្សេងៗ ដូចជា ខ្សែក្រវាត់ កាបូប ស្បែកជើង ។ល។
- ផ្តល់នូវលាមកដ៏មានតំលៃ សំរាប់យកទៅដាក់ស្រែ និងដំណាំដ៏ទៃទៀត (លាមករបស់ពពែសំបូរជាតិអាហ្សូត ជាងលាមករបស់គោ ក្របី)

## ២. ពូជ

ពូជពពែដែលកសិករចិញ្ចឹមតាមភូមិ ច្រើនជាពូជដែលគាត់ពុំដឹងច្បាស់លាស់ គាត់ទិញពូជពីអ្នកជិតខាង ពីភូមិជិតៗ ឬក៏ទិញមកពីតំបន់ផ្សេង។

ការចិញ្ចឹមពពែនៅក្នុងប្រទេសកម្ពុជាច្រើនប្រព្រឹត្តទៅជាលក្ខណៈគ្រួសារ ពូជពពែដែលកសិករចិញ្ចឹម មានមាឌធំ មធ្យម ពិណស ខ្មៅ ក្រហម ឬពិណសលាយខ្មៅ ។ល។



**រូបភាពទី ១: ពូជពពែដែលកសិករចិញ្ចឹមក្នុងស្រុក**

## ៣. ការជ្រើសរើសពូជ និងការបង្កាត់ពូជ

ការចិញ្ចឹមពពែដែលផ្តល់ផលខ្ពស់ត្រូវចាប់ផ្តើមពីកូនពពែដែលមានសុខភាពល្អមាំមួន និងស្វាហាប់។ ចំពោះការជ្រើសរើស និងបង្កាត់ពូជបានល្អយើងត្រូវផ្តោតលើចំណុចសំខាន់ៗចំនួន៣ៈ

- ត្រូវមានពពែបាល្អ
- មានមេពពែសុខភាពល្អ

- ត្រួតពិនិត្យការរកឈ្មោលរបស់មេពពែឱ្យបានត្រឹមត្រូវ



រូបភាពទី ២: កូនពពែ និងមេដែលមានសុខភាពល្អ និងមាំមួន

### ៣.១. ការជ្រើសរើសពពែបា

ពពែបាត្រូវតែមានលក្ខណៈដូចខាងក្រោមនេះ

- មានមាឌធំ និងសុខភាពល្អមាំមួន ជាពពែដែលមានភាពខ្លាំងក្លាជាងគេក្នុងហ្វូង
- មានគ្រោងដងខ្លួនល្អតលាស់ល្អ
- ជើងទាំង ៤ រឹងមាំល្អ និងក្រចកជើងជិតល្អ
- ខ្នងរាងត្រង់ និងព្រែក
- មានប្រដាប់បន្តពូជល្អ និងពងស្វាសល្អតលាស់ល្អ (ពងស្វាសទាំងគូស្មើគ្នា)
- អាចពាក់មេបានច្រើន
- ស្លូត មិនដើរជល់ជាមួយពពែផ្សេងទៀត
- មានរាងសង្ហា ហើយជាការល្អមិនមានស្នែង
- មិនរើសចំណី



**រូបភាពទី ៣: ពពែបាសំរាប់ធ្វើពូជ**

ពពែបាដែលទុកធ្វើពូជត្រូវតែជ្រើសរើសដោយប្រុងប្រយ័ត្ន។ យើងត្រូវជ្រើសយកពពែឈ្មោលដែលល្អបំផុតពីមេដែលសំបូរទឹកដោះ និងសាយកូន ពពែឈ្មោលដែលមានសុខភាពល្អលូតលាស់ល្អ អាចប្រើសំរាប់បង្កាត់ពូជក្នុងអាយុពី ១១-១២ ខែ ទំងន់របស់វាតិចបំផុត ២៥ គីឡូក្រាម។ បានៅក្មេងមិនត្រូវប្រើវាហួសកំណត់ទេ ដែលជាហេតុធ្វើឱ្យវាបាក់ និង ពន្យឺត ការលូតលាស់របស់វា។

ពពែបាត្រូវតែថែរក្សា និងផ្តល់ចំណីឱ្យបានត្រឹមត្រូវ ជាពិសេសក្នុងកំឡុងពេលពាក់មេច្រើនដង ត្រូវផ្តល់ចំណីបៃតងដែលមានគុណភាពខ្ពស់ និងផ្តល់នូវចំណីផ្សំបន្ថែម (១៥០ ក្រាម/ថ្ងៃ)។

ជាការល្អយើងគួរតែបំបែកបាចេញពីពពែញី និងពពែឈ្មោលផ្សេងទៀត។ ជាធម្មតាពពែបាពេញវ័យមួយអាចបំរើពពែញីប្រហែលពី ២០-៣០ ក្បាល។

ដើម្បីជៀសវាងការបង្កាត់ពូជតែមួយ ឬឈាមតែមួយគេត្រូវផ្លាស់ប្តូរពពែបាជាទៀងទាត់ បន្ទាប់ពី ១៨ ខែ ឬបន្ទាប់ពីជាន់មេបានពីររដូវ។

## ៣.២. ការក្រៀវពពែ

មានតែបាដែលជ្រើសរើសទើបអនុញ្ញាតិឱ្យពាក់មេពពែក្នុងហ្វូង។ ពពែដែលមិនទុកបង្កាត់ពូជត្រូវក្រៀវវា។ ការក្រៀវពពែធ្វើឱ្យវា:

- ស្ងប់ស្ងៀម និង
- ងាយឃ្វាល

ហេតុដូចនេះយើងអាចចិញ្ចឹមវាជាមួយពពែញីផ្សេងទៀតដោយគ្មានគ្រោះថ្នាក់ មិនជល់គ្នា និងពុំធ្វើឱ្យមានរបួស។

ពពែត្រូវបានក្រៀវដោយប្រើដង្កាប់ម្យ៉ាង (Burdizzo or Emasculator) ឧបករណ៍នេះត្រូវបានប្រើដោយបសុពេទ្យ ឬអ្នកដែលមានបទពិសោធន៍។ ពពែដែលមានអាយុពី ៦-៨ ខែ ត្រូវបានក្រៀវដោយឧបករណ៍នេះ (រូបទី ៤) ឬត្រូវក្រៀវដោយឧបករណ៍ម្យ៉ាងទៀតឈ្មោះ Elastrator Rubber Rings (រូបទី ៤) ឧបករណ៍នេះត្រូវបានប្រើចំពោះសត្វដែលមានអាយុមិនដល់ ២ ខែ និងចំពោះកូនពពែញីមានអាយុពី ២-៤ សប្តាហ៍។ ដើម្បីការពារជង្គឺដែលបណ្តាលមកពីការក្រៀវនេះ គួរជៀសវាងការក្រៀវសត្វក្នុងរដូវភ្លៀង។

ឧបករណ៍ Elastrator Rubber Rings មានភាពងាយស្រួលក្នុងការប្រើ។ ជាដំបូងយើងត្រូវសំលាប់មេរោគលើពងស្វាសដោយប្រើថ្នាំសំលាប់មេរោគ បន្ទាប់មកយើងសំលាប់មេរោគលើឧបករណ៍។ យើងពន្លាតឧបករណ៍នេះរួចច្របាច់ទៅលើពងស្វាស។ នឹងដាច់ធ្លាក់បន្ទាប់ពី ៣-៤ សប្តាហ៍ ក្នុងកំឡុងពេលនេះយើងត្រូវប្រើទឹកថ្នាំសំលាប់មេរោគទៅលើមុខរបួស។



**រូបភាពទី ៤: ឧបករណ៍សំរាប់ក្រៀវពពែ** (Burdizzo និង Elastrator Rubber Rings)

## ៣.៣. ពពែញីទុកធ្វើពូជ

ការជ្រើសរើសមេពពែល្អមានសារៈសំខាន់សំរាប់ផលិតកម្មពពែ ព្រោះកូនរបស់វាអាចទទួលនូវលក្ខណៈល្អ និងអាក្រក់ពីមេ។ អាស្រ័យហេតុនេះមេពពែសំរាប់ទុកធ្វើពូជគួរតែជ្រើសរើសមេណាដែលផ្តល់ទឹកដោះច្រើន និងផលិតកូនច្រើន។

មេពពែដែលល្អត្រូវមានលក្ខណៈដូចខាងក្រោម:

- មានរាងមាំ និងសុខភាពល្អ
- ផលិតកូនទៀងទាត់ពី ៨-៩ ខែម្តង
- មេស្លូត និងចេះថែរក្សាកូនបានល្អ

- ផ្តល់កូនភ្លោះញឹកញាប់
- ផលិតទឹកដោះគ្រប់គ្រាន់សំរាប់ចិញ្ចឹមកូនពពែ ២ (សំបូរទឹកដោះ)
- មានដោះធំទូលាយ និងមានចុងដោះស្មើត្រង់ទៅមុខ
- មិនរើសចំណី

ទំរង់ដងខ្លួនដែលចង់បាន:

១. ដងខ្លួនវែង មាំ និងត្រគាកធំទូលាយ

២. ខ្នងត្រង់ មិនអើន ទ្រូងរាងជត ទូលាយ

៣. កន្សោមដោះធំ ក្បាលដោះវែងល្អ

៤. ជើងត្រង់មាំល្អ



**រូបភាពទី ៥: ពពែញីដែលល្អសំរាប់ទុកពូជ**

កន្សោមដោះដែលមានរាងមិនល្អ:

- កន្សោមដោះមិនជាប់ទៅនឹងពោះ
- មានចុងដោះក្រាស់
- មានចុងដោះតូច
- កន្សោមដោះចែកជាពីរ កន្សោមដោះយារ
- ដោះទាំងសងខាងមិនស្មើគ្នា



រូបភាពទី ៦: មេពពែដែលមានកន្សោមដោះមិនល្អ (កន្សោមដោះយារ)



រូបភាពទី ៧: កន្សោមដោះមិនល្អ



រូបភាពទី ៨: មេពពែដែលមានកន្សោមដោះល្អ

ពពែដែលមានទំរង់ជើងមិនល្អ (Incorrect Leg Position):



ជង្គង់ឃ្លាតឆ្ងាយពីគ្នា (រាងជាអក្សរ O)　　ជង្គង់ទាំងពីរជិតគ្នាពេក (រាងជាអក្សរ X)

**រូបភាពទី ៩: ទំរង់ជើងមិនល្អ**

## ៣.៤. ដំណើរការនៃការបន្តពូជ

ជាធម្មតាការរកឈ្មោលរបស់ពពែញី (វដ្តនៃការរកឈ្មោល) មានរយៈពេលពី ១៨-២១ ថ្ងៃ។ ជាទូទៅលក្ខណៈសំគាល់ពពែញីរកឈ្មោលមានៈ

- ប្រដាប់បន្តពូជឡើងរីកធំ ពណ៌ក្រហម
- ទឹករំអិលពណ៌សមានលាយពណ៌លឿងព្រឿងៗ ហូរចេញមកពីប្រដាប់បន្តពូជ
- សត្វនៅមិនស្ងៀម ឆ្លេឆ្លា បាត់បង់នូវការឃ្លានចំណី
- ស្រែករោទ៍ ញីកញ្ជប់ និងនោមញឹក
- គ្រវីកន្ទុយ ហើយចូលចិត្តសត្វឈ្មោល
- ចូលចិត្តឡើងពាក់សត្វដ៏ទៃទៀត

នៅក្នុងកំឡុងពេលមេពពែបញ្ចេញសញ្ញារកឈ្មោលនេះ គឺជាពេលដែលអាចដាក់បាន ប្រសិនបើហួសពេលនេះមាត់ស្បូននឹងបិទវិញ នោះការបង្កាត់ពូជមិនទទួលបានជោគជ័យទេ។ បើទុកឱ្យពេលនេះកន្លងផុត អ្នកត្រូវរងចាំ ២១ ថ្ងៃក្រោយទៀត ដែលធ្វើឱ្យខាតបង់ពេលវេលា។

ការដាក់ឈ្មោលបានជោគជ័យមានរយៈពេលខ្លី ប្រហែល ៦-១២ ម៉ោងប៉ុណ្ណោះ ដូច្នេះអ្នកត្រូវយកចិត្តទុកដាក់តាមដានមេពពែឱ្យបានត្រឹមត្រូវ។ រយៈពេលផើម ៥ ខែ គិតចាប់ពីថ្ងៃដាក់ឈ្មោលបានជោគជ័យ។

ប្រសិនបើការដាក់ឈ្មោលបានសំរេច ពពែញីមិនរកឈ្មោលទៀតទេ។ ការដាក់ឈ្មោលមិនបានសំរេចសត្វបង្ហាញពីការរកឈ្មោលម្តងទៀត នៅពេលនេះចាំបាច់ត្រូវដាក់ឈ្មោលជាលើកទី ២។ ក្រោយពីការដាក់ឈ្មោលជាលើកទី ២ ហើយវានៅតែរកឈ្មោលទៀត បញ្ហានេះអាចបណ្តាលមកពីមេពពែ ឬពពែបា។ ក្នុងករណីនេះអ្នកអាចហៅបសុពេទ្យមកធ្វើការត្រួតពិនិត្យ។

**ចំណាំ:** អ្នកត្រូវកត់ត្រាទុកនូវថ្ងៃខែឆ្នាំពេលកើត ពេលចង់ឈ្មោល ពេលដាក់ឈ្មោល និងពេលកើតកូនរបស់មេពពែ។

របៀបចុះបញ្ជីដែលអាចជួយដល់អ្នកចិញ្ចឹមពពែ:

- ត្រួតពិនិត្យមើលតើពពែធើម ឬបង្ហាញពីការរកឈ្មោលទៀតបន្ទាប់ពីដាក់ឈ្មោលបានពី ១៨-២៣ ថ្ងៃ
- ធ្វើកាលវិភាគសំរាប់ពពែបា
- គណនា និងគិតទុកនូវថ្ងៃខែឆ្នាំកើតកូនរបស់ពពែញី
- គណនាកត់ត្រាទុកនូវការរកឈ្មោលជាលើកដំបូងរបស់ពពែញីពេលទើបពេញវ័យ
- ជ្រើសរើសកូនពពែញីចេញពីមេពពែដែលផ្តល់ផលខ្ពស់សំរាប់ការបង្កាត់ពូជ

មេពពែដែលផ្តល់ទិន្នផលខ្ពស់គឺជាកត្តាមួយសំខាន់បំផុតក្នុងការផ្តល់ប្រាក់ចំណេញសំរាប់ផលិតកម្មនៃការចិញ្ចឹមពពែ។

មេពពែដែលផ្តល់ទិន្នផលទាបធ្វើឱ្យមិនចំណេញក្នុងការចិញ្ចឹម ព្រោះវាខាតបង់កំលាំងពលកម្មច្រើន ត្រូវការចំណីច្រើន ហើយផលិតកូនតិចដោយប្រើរយៈពេលយូរ។

សរុបមកចំនុចសំខាន់ៗដែលអ្នកគួរដឹងទាក់ទងទៅនឹងការជ្រើសរើស និងបង្កាត់ពូជពពែមានដូចខាងក្រោមនេះ

- ពពែបាដែលជ្រើសរើសទុកពូជទើបអនុញ្ញាតិឱ្យពាក់មេ ចំណែកពពែឈ្មោលដែលមិនទុកពូជត្រូវតែក្រៀវ
- ប្តូរបាបន្ទាប់ពី ១៨ ខែ
- អាយុ និងទំងន់តិចបំផុតរបស់ពពែបា: ១១ ខែ ឬ ២៥ គីឡូក្រាម
- ពពែបាពេញវ័យអាចពាក់ពពែញីបានពី ២០-៣០ ក្បាល
- ជ្រើសរើសពពែញីសំរាប់ធ្វើការបង្កាត់ពូជចេញពីមេពពែដែលផ្តល់ទឹកដោះច្រើន និងទិន្នផលខ្ពស់
- អាយុអប្បរមារបស់ពពែញីអាចដាក់ឈ្មោលជាលើកដំបូងគឺពី ១១-១២ ខែ

- សង្កេតដោយប្រុងប្រយ័ត្ននូវសញ្ញានៃការរកឈ្មោលរបស់ពពែញី
- រៀបចំកាលវិភាគសំរាប់ពពែបា
- ចុះបញ្ជីឱ្យបានត្រឹមត្រូវនូវថ្ងៃខែរកឈ្មោល ការដាក់ឈ្មោល និងការកើតកូនរបស់ពពែញី

## ៤. ទ្រុង

ទ្រុងពពែដែលល្អមានសារៈសំខាន់:

- ផ្ដល់ល័ក្ខខ័ណ្ឌល្អសំរាប់ការរស់នៅដល់សត្វ និងធ្វើឱ្យសត្វមានសុខភាពល្អ
- ការពារសត្វពពែ ជាពិសេសកូនរបស់វា

សំភារៈដែលងាយរកសំរាប់សាងសង់ទ្រុងពពែរួមមានៈ

- ◆ ឈើសំរាប់ធ្វើសសរ និងជើងសសរសំរាប់ទ្រកុំឱ្យពុក
- ◆ រនាប ឬក្ដារបន្ទះសំរាប់ក្រាលបាត ជញ្ជាំងអាចធ្វើពីឫស្សី ឬបន្ទះឈើតូចៗ
- ◆ ដំបូលអាចប្រក់ស្លឹកត្នោត ឬស្លឹកស្បូវក្រងជាកណ្ដាប់
- ◆ ដែកគោលសំរាប់ដំភ្ជាប់រនាប និងជញ្ជាំង ។ល។
- ◆ ដែកលួសសំរាប់ចងភ្ជាប់ផ្សេងៗ ។ល។

យើងអាចចែកទ្រុងជាពីរប្រភេទ:

- ទ្រុងដែលសង់ផ្ទាល់ដី និង
- ទ្រុងសង់ផុតពីដី

### ៤.១. ទ្រុងពពែដែលសង់ផ្ទាល់ដី

ទ្រុងដែលសង់ផ្ទាល់ដីវាសមស្របទៅនឹងតំបន់ស្ងួត វាងាយស្រួលក្នុងការសង់ និងដោយត្រូវការរបងព័ទ្ធជុំវិញ។ ដីបាតទ្រុងលើកឱ្យមានកំពស់ប្រហែល ៣០ សង់ទីម៉ែត្រ និងធ្វើឱ្យមានជំរាលបន្ដិច។ ធ្វើយ៉ាងនេះងាយស្រួលក្នុងការបង្ហូរកាកសំណល់ លាមក និងទឹកនោមចេញក្រៅ ហើយដែលអាចរក្សាទ្រុងស្ងួតជាប្រចាំ។



**រូបភាពទី ១០: ទ្រុងពពែដែលសង់ផ្ទាល់ដី**

ក្នុងការសង់ទ្រុងប្រភេទនេះកសិករអាចប្រើសំភារៈដែលមានក្នុងភូមិ ដូចជា កូនឈើ ឫស្សី ក្តារបន្ទះ ហើយដំបូលប្រក់ស្លឹក ។ល ។

## ៤.២. ទ្រុងពពែដែលសង់ផុតពីដី

ការសង់ទ្រុងបែបនេះទាមទារការពិនិត្យបានល្អិតល្អន់ និងត្រូវការសំភារៈសាងសង់ច្រើន ក៏ប៉ុន្តែវាមានលក្ខណៈងាយស្រួលដែរក្នុងការសាងសង់ ។ កំពស់របស់ទ្រុងប្រហែល ១ ម៉ែត្រពីដី សត្វពពែអាចឡើងទៅលើទ្រុងតាមជណ្តើរជំរាល ជណ្តើរឡើងត្រូវសង់ឱ្យមានបង្កាន់ដៃដើម្បីការពារកុំឱ្យសត្វធ្លាក់ ។ ពពែរស់នៅដោយសុខស្រួលក្នុងទ្រុងប្រភេទនេះ វាជាសត្វដែលចូលចិត្តទ្រុងបែបនេះ ហើយដែលធ្វើឱ្យវាលូតលាស់ល្អ និងផ្តល់ផលខ្ពស់ ពីព្រោះទ្រុងប្រភេទនេះមានសារៈប្រយោជន៍ច្រើន ការពារសត្វពពែពីៈ

- ភ្លៀង ខ្យល់ខ្លាំង និងកំដៅព្រះអាទិត្យខ្លាំង
- ការចំលងមេរោគ និងជំងឺ
- ចោរលួច និងសត្វព្រៃ

សារៈសំខាន់ផ្សេងទៀតៈ

- ខ្យល់ចេញចូលល្អ
- ងាយស្រួលក្នុងការសំអាត
- ងាយស្រួលក្នុងការប្រមូលលាមក និងផ្តល់លាមកល្អ



**រូបភាពទី ១១: ទ្រុងពពែសង់ផុតពីដី**

អាស្រ័យហេតុនេះទ្រុងដែលសង់ផុតពីដីនាំមកនូវគុណសម្បត្តិសំខាន់ៗដូចជា:

- ទ្រុងផ្តល់នូវភាពស្ងួត និងធ្វើឱ្យពពែមិនរងា
- ធ្វើឱ្យចំណីស្អាតមិនប្រឡាក់ ស្ងួត និងមានរសជាតិ ហើយដែលចំណីមិនសល់ចោល
- ផ្តល់នូវម្លប់ដ៏ត្រជាក់ និងការពារសំណើម ហើយធ្វើឱ្យសត្វចង់ស៊ីចំណី
- កាត់បន្ថយពីការលួច និងកាត់បន្ថយពីការបំផ្លាញដោយសត្វព្រៃ

ទ្រុងដែលសង់ផុតពីដីមានភាពងាយស្រួលចំពោះពពែ និងអ្នកចិញ្ចឹម។ ទ្រុងប្រភេទនេះបង្កលក្ខណៈល្អចំពោះសុខភាពសត្វ ដូច្នេះពពែ និងកូនរបស់វាមានសុខភាពល្អ និងធំធាត់លឿន។

កសិករគួរសង់ទ្រុងដោយមានការបែងចែក សំរាប់មេធើម មេបំបៅកូន សំរាប់ពពែបា និងសំរាប់ពពែជំទង់ ការធ្វើទ្រុងរបៀបនេះដើម្បីជៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដូចជាការជល់គ្នា ឬជាន់កូនពពែងាប់ដែលបណ្តាលឱ្យខាតបង់ថវិកា។

ទំហំរបស់ទ្រុងត្រូវគណនាឱ្យសមស្របទៅនឹងចំនួនរបស់ពពែ ព្រោះបើទ្រុងតូចចង្អៀតវាបណ្តាលឱ្យប៉ះពាល់ដល់ការលូតលាស់របស់សត្វ។ ទ្រុងគំរូសំរាប់សត្វពពែ ២២ ក្បាល មានទំហំ ៣ ម៉ែត្រ x ៥ ម៉ែត្រ:

- ពពែញី ៦ ក្បាល
- ពពែឈ្មោល (បា) ១ ក្បាល
- កូនពពែ ១៥ ក្បាល

**តារាងទី ១: តម្រូវការផ្ទៃក្រឡាទ្រុងសំរាប់ពពែ ១ ក្បាល**

| ប្រភេទពពែ | ផ្ទៃក្រឡា (ម$^{២}$)/១ក្បាល |
|---|---|
| កូនពពែ | 0.៥ |
| ពពែជំទង់ | ១.២ |
| ពពែញី | ១.៥ |
| ពពែឈ្មោល | ២-២.៥ |
| ពពែបំបៅកូន | ២-២.៥ |
| ពពែបា | ២-២.៨ |

ម$^{២}$ = ម៉ែត្រក្រឡា

## ៤.៣. តើអ្នកត្រូវសង់ទ្រុងពពែនៅកន្លែងណា?

អ្នកគួរជ្រើសរើសទីកន្លែងសំរាប់សាងសង់ទ្រុងដោយយកចិត្តទុកដាក់ ទីកន្លែងសមស្របសំរាប់សង់ទ្រុងពពែ:

- ស្ងួត មិនដក់ទឹក
- មានម្លប់ ក្រោមដើមឈើ
- មានខ្យល់ចេញចូលល្អ
- ជៀសផុតពីទិសខ្យល់ខ្លាំង (ត្រជាក់ និងក្តៅ) និងភ្លៀង
- ចែកឱ្យដាច់ពីហ្វូងគោ/ក្រោលគោ
- យកល្អ ទ្រុងពពែត្រូវធ្វើចំងាយប្រហែល ១៨ ម៉ែត្រពីកសិដ្ឋាន

ត្រូវប្រុងប្រយ័ត្នចំពោះបន្ទះក្តារដែលយកមកក្រាលបាតទ្រុង:

ចន្លោះរវាងបន្ទះក្តារតូចពេក → ធ្វើឱ្យទ្រុងកខ្វក់ ពីព្រោះកាកសំណល់និងលាមកសត្វមិនអាចស្រក់ទៅដីបាន

ចន្លោះរវាងបន្ទះក្តារធំ → អាចធ្វើឱ្យរបួសក្រចកជើង និងជើងរបស់សត្វ

អាស្រ័យហេតុនេះ:

១. ចន្លោះរវាងបន្ទះក្តារត្រូវគណនាឱ្យបានត្រឹមត្រូវ (0.៥-១ សង់ទីម៉ែត្រ)

២. បន្ទះក្តារត្រូវស្ងួត និងធន់គ្រប់រដូវ ដែលមិនធ្វើឱ្យវារីកមាឌ ឬ រួញខ្លី

ធ្នើរ ឬទ្រុងសំរាប់ដាក់ស្មៅ

- ចំពោះទ្រុងដែលសង់ផុតពីដី គេអាចប្រើទ្រុងដាក់ស្មៅដែលភ្ជាប់ទៅនឹងជញ្ជាំង ទ្រុងប្រភេទនេះសំរាប់ដាក់ស្មៅ និងចំណីបៃតងផ្សេងទៀត ហើយដែលអាចកាត់បន្ថយនូវការខ្ជះខ្ជាយចំណី ។
- ប្រភេទធ្នើរ ឬទ្រុងសំរាប់ដាក់ចំណីផ្សេងទៀតដោយមិនចាំបាច់ភ្ជាប់ទៅនឹងជញ្ជាំង ដែលគេច្រើនប្រើសំរាប់ទ្រុងសង់ផ្ទាល់ដី

លាបពិណទ្រុងដែលធ្វើហើយដោយប្រើប្រេងម៉ាស៊ីនដែលប្រើរួច ធ្វើយ៉ាងនេះដើម្បីការពារទ្រុងមិនឱ្យឆាប់ពុក និងធ្វើឱ្យជាប់បានយូរ ។ ទ្រុងកាន់តែជាប់បានយូរកាលណាគេថែរក្សា និងជួសជុលវាម្យ៉ាងទៀត គេត្រូវលាបប្រេងម៉ាស៊ីនជារៀងរាល់ឆ្នាំ ហើយដំបូលដែលប្រក់ស្បូវត្រូវផ្លាស់ប្តូរវាទៀងទាត់ក្នុងរយៈពេល ២ ឆ្នាំម្តង ។



**រូបភាពទី ១២: ធ្នើរ ឬទ្រុងសំរាប់ដាក់ស្មៅ ដោយភ្ជាប់ទៅនឹងជញ្ជាំង**

ការដែលធ្វើទ្រុងបានល្អ អាចធ្វើឱ្យយើងមានសារៈប្រយោជន៏ះ

- កាត់បន្ថយនូវការស្លាប់របស់ពពែ និងកូនរបស់វា ដែលមិនធ្វើឱ្យខាតបង់ថវិកាច្រើន
- ការពារជំងឺ និងកាត់បន្ថយការព្យាបាលផ្សេងៗ

- ធ្វើឱ្យសត្វមានសុខភាពល្អ បង្កើនការលូតលាស់ធំធាត់របស់សត្វ

ទាំងនេះជាលទ្ធផលដែលធ្វើឱ្យផលិតកម្មពពែទទួលបាននូវប្រាក់ចំណេញច្រើន ។

## ៥. ការថែទាំមេពពែជើម

ការថែទាំមេពពែបានល្អ និងផ្តល់ចំណីបានត្រឹមត្រូវ នឹងអាចទទួលបានកូនពពែសុខភាពល្អមាំមួន ។ ការថែរក្សាមេពពែជើមបានត្រឹមត្រូវគឺជាការវិនិយោគមួយសំរាប់ពេលខាងមុខ:

- អាចជាសះស្បើយឡើងវិញពីភាពតានតឹងនៃការបង្កើតកូន
- ផលិតទឹកដោះច្រើនសំរាប់កូន
- ឆាប់ដាក់ឈ្មោលបានម្តងទៀត

ក្នុងកំឡុងពេលជើម ៣ ខែដំបូងមេពពែមិនត្រូវបានថែរក្សាពិសេស ឬថែរក្សាដាច់ដោយឡែកនោះទេ គេអាចផ្តល់ចំណីឱ្យវា ឬឱ្យស៊ីស្មៅជាមួយហ្វូងពពែ និងបន្តការទំលាក់ព្រូនដោយគ្មានការប៉ះពាល់ដល់មេ និងកូន ។

ក្នុងកំឡុងពេលខែទី ៤ និងទី ៥ កូនពពែនៅក្នុងពោះកើនទំងន់យ៉ាងឆាប់រហ័ស អាស្រ័យហេតុនេះមេពពែជើមទាមទារនូវការថែទាំ និងផ្តល់ចំណីពិសេស:

- កាត់បន្ថយការលែងឱ្យស៊ីស្មៅតាមវាល
- បន្ថែមចំណីបៃតងដែលមានគុណភាពខ្ពស់ក្នុងក្រោល
- បញ្ឈប់ការលែងឱ្យស៊ីលើវាលស្មៅ យឺតបំផុត ២ សប្តាហ៍មុនពេលកើតកូន
- បង្ខាំងមេពពែជិតគ្រប់ខែក្នុងទ្រុងដាច់ដោយឡែកពីហ្វូង ដើម្បីជៀសវាងការរលូតកូន
- ផ្តល់នូវអំបិលខនិជសំរាប់សត្វលិត និងទឹកស្អាតគ្រប់ពេលវេលា
- ផ្តល់ចំណីផ្សំ ៤០០ ក្រាម រៀងរាល់ថ្ងៃចាប់ពីជើម ៥ ខែឡើងទៅ ឧទាហរណ៍: កាកខ្ទិះដូង ៤០% លាយកន្ទក់ ៦០%



**រូបភាពទី ១៣: ការថែទាំមេពពែដើម**

## ៦. ការបង្កើតកូនពពែ

ជាទូទៅរយៈពេលពពែដើមគឺពី ១៤៥-១៥៥ ថ្ងៃ។ អ្នកចិញ្ចឹមពពែត្រូវកត់ត្រាឱ្យបានត្រឹមត្រូវ ដើម្បីដឹងឱ្យបានច្បាស់លាស់ពីពេលវេលានៃការកើតកូនរបស់វា។ ប្រហែល ២ សប្តាហ៍មុនពេលកើត ត្រូវរៀបចំទ្រុង សំរាប់បង្កើតកូនឱ្យបានត្រឹមត្រូវ។ កន្លែងបង្កើតកូនត្រូវស្អាតស្ងួត មានខ្យល់ចេញចូលល្អ គួរក្រាលចំបើងពីក្រោមសំរាប់កូនពពែនិងមេ ពីព្រោះចំបើងបឺតយកសារធាតុរាវ ហើយអាចបំបាត់ក្លិនស្អុយបានខ្លះ។ ក្រៅពីនេះត្រូវមានក្រណាត់ស្អាតសំរាប់ជូតកូនរបស់វានៅពេលកើត និងរៀបចំសូលុយស្យុង អ៊ីយ៉ូដឌីន (iodine solution) ៧ ភាគរយ សំរាប់ជ្រលក់ទងផ្ចិតសំលាប់មេរោគ។ អ៊ីយ៉ូដឌីន ជាថ្នាំរាវប្រើសំរាប់សំលាប់មេរោគ នៅលើមុខរបួស និងអាចរកទិញបាននៅលើទីផ្សារ។

កំណត់សំគាល់មេពពែជិតកើតកូនៈ

- មានភាពរសាប់រសល់ កាយកំរាលទ្រុង ហើយស្រែកបញ្ចេញសំឡេង
- បាត់បង់ការឃ្លានចំណី
- ដកដង្ហើមញាប់
- បែរក្រោយញឹក
- ក្រពេញដោះឡើងរីកធំ ហើយចុងដោះឡើងរឹង
- ប្រដាប់បន្តពូជរីកធំ ឡើងប៉ោងក្រហម ហើយសើមនិងមានទឹករំអិលពិណសខាប់

មុននឹងបង្កើតកូនត្រូវកាត់រោមជុំវិញកន្ទុយ និងផ្នែកខាងក្រោយចោល។ ជិតដល់ពេលកើតកូន ត្រូវសំអាតផ្នែកខាងក្រោយដោយសាប៊ូ និងទឹកក្តៅ រួចជូតឱ្យស្ងួត។ ការរៀបចំទាំងនេះគឺការពារមេ និងកូន មិនឱ្យទទួលនូវការឆ្លងមេរោគផ្សេងៗ។



**រូបភាពទី ១៤: ការកាត់សំអាតរោមខាងក្រោយរបស់មេពពែមុនកើតកូន**

## ៦.១. ការបង្កើតកូនធម្មតា

ជាធម្មតាមេពពែបង្កើតកូនដោយគ្មានបញ្ហា រៀបនឹងកើតមេពពែទំរេតខ្លួនលើកំរាលទ្រុង ថង់ទឹកភ្លោះលៀនចេញមក បន្ទាប់មកថង់ទឹកភ្លោះក៏បែក នោះបញ្ជាក់ថាការកើតកូនចាប់ផ្តើម។ ក្នុងពេលដ៏ខ្លីជើងមុខទាំងពីររបស់កូនពពែត្រូវបានឃើញមុនគេ បន្ទាប់មកទៀតយើងនឹងឃើញក្បាលរបស់វា។ នេះជាស្ថានភាពបង្កើតកូនធម្មតា។ ក្នុងរយៈពេលដ៏ខ្លីកូនពពែត្រូវបានកើត ពេលវេលា ទាំងអស់សំរាប់ការបង្កើតកូនមិនលើសពី ៣០ នាទីឡើយ។

ជាធម្មតាមេពពែលិតសំងួតកូនរបស់វា សំអាតរំអិលនៅនឹងច្រមុះ មាត់ ដែលអាចធ្វើឱ្យកូនរបស់វាចាប់ផ្តើមដកដង្ហើមបាន។ យើងអាចជួយកូនពពែដែលទើបកើតដោយប្រើចំបើង ឬក្រណាត់ស្អាតជូត។ ដើម្បីការពារផ្ចិតពីការចំលងមេរោគ (ការចំលងដោយដង្កូវ ឬតេតាណូស) យើងត្រូវកាត់ខ្សែផ្ចិតរបស់កូនពពែ ក្នុងចំងាយពីពោះប្រហែល ៥ សង់ទីម៉ែត្រ ហើយត្រូវប្រើថ្នាំសំលាប់មេរោគដោយប្រើទឹកអ៊ីយ៉ូដ។ ក្នុងករណីកូនភ្លោះ ឬកើតកូន ៣ រយៈពេលកើតពីមួយទៅមួយប្រហែល ១៥ នាទី។ បន្ទាប់ពីកូនចុងក្រោយត្រូវបានបង្កើត ជាធម្មតាសុកនឹងធ្លាក់មកក្នុងរយៈពេលពី ៤-៥ ម៉ោង។ ចុងបញ្ចប់កន្ទ្រោមដោះនិងផ្នែកខាងក្រោយរបស់មេពពែត្រូវសំអាតដោយយកចិត្តទុកដាក់ដោយ សាប៊ូ និងទឹកក្តៅ។ សំភារៈ

ដែលប្រើប្រាស់ក្នុងពេលបង្កើតកូន និងសុកត្រូវយកចេញអោយឆ្ងាយ រួចហើយត្រូវសំអាតទ្រុង។ មេពពែត្រូវផ្តល់ទឹកក្តៅ និងបបររាវឱ្យវាស៊ី។

កូនពពែដែលទើបកើតត្រូវដាក់ក្នុងសំបុក (ទ្រុង) ដែលមានបណ្តោយ ១ ម៉ែត្រ ទទឹង ០.៥ ម៉ែត្រ និងកំពស់ ០.៥ ម៉ែត្រ ដោយមានក្រាលចំបើងពីក្រោមផង។ ទ្រុងនេះការពារកូនពពែពីភាពត្រជាក់ និងមិនធ្វើឱ្យវារលាកសួត។



**រូបភាពទី ១៥: ទ្រុងសំរាប់កូនពពែដែលទើបកើត**

## ៦.២. ការជួយមេពពែក្នុងពេលកើតកូន

គេអាចជួយដោយខ្លួនឯងប្រសិនបើពេលកើតកូនពពែស្ថិតនៅទីតាំងធម្មតា ជាពិសេសទៅទៀតក្នុងករណីកូនភ្លោះ ឬកូនម្តង ៣ ឬមួយក៏មេពពែទើបតែបង្កើតកូនជាលើកដំបូង។

ការជួយមេពពែចាំបាច់:

- នៅពេលការបង្កើតកូនពន្យារពេលចាប់ពី ៣០ នាទី ឡើងទៅចាប់ពីលេចចេញនូវជើងមុខរបស់កូនពពែ
- នៅពេលគ្មានដំណើរការទៅមុខរហូតដល់ ១០ នាទី បន្ទាប់ពីបែកទឹកភ្លោះ
- ជើងមុខចេញមកតែបត់ទៅក្រោយ
- កូនកើតផ្ងា ហើយមានតែជើងម្ខាងចេញមកក្រៅ

ជាដំបូងអ្នកត្រូវលាងដៃជាមួយនឹងសាប៊ូឱ្យបានស្អាតត្រឹមត្រូវ បន្ទាប់មកត្រូវទាញជើងរបស់កូនពពែដោយថ្នមៗ។



**រូបភាពទី ១៦: ការជួយមេពពែក្នុងពេលកើតកូន**

អ្នកត្រូវហៅពេទ្យសត្វជួយជាបន្ទាន់នៅពេលៈ

- ការជួយរបស់អ្នកប្រព្រឹត្តទៅមិនបានជោគជ័យ
- នៅពេលកើត កូនពពែស្ថិតនៅទីតាំងមិនធម្មតា (ជើងក្រោយចេញមកមុន)
- ការកើតពន្យារពេលជ្រុល ច្រើនជួបប្រទះចំពោះករណីកូនភ្លោះ ឬកូន ៣
- ក្នុងរយៈពេល ២៤ ម៉ោងសុកមិនទាន់ធ្លាក់បន្ទាប់ពីកូនចុងក្រោយត្រូវបានកើត
- ការពន្យារកំណើតលើសពី ១ សប្តាហ៍

## ៦.៣. ការចិញ្ចឹមកូនពពែ

ក្នុងរយៈ ៣ ខែដំបូងគឺជាកំឡុងពេលប្រកបដោយគ្រោះថ្នាក់សំរាប់កូនពពែដែលទើបកើត។ អាស្រ័យហេតុនេះត្រូវថែរក្សាកូនពពែនិងមេវាឱ្យបានហ្មត់ចត់ជាទីបំផុតក្នុងកំឡុងពេលនេះ:

- ទ្រុងពពែត្រូវស្ងួត និងស្អាតជានិច្ច នាំឱ្យជៀសផុតពីជំងឺរាគ
- ការពារកូន និងមេពពែពីខ្យល់ និងភាពត្រជាក់ នាំឱ្យជៀសផុតពីជំងឺរលាកសួត
- ទឹកដោះមេពពែគឺល្អបំផុតសំរាប់កូនរបស់វា រហូតដល់អាយុផ្តាច់ដោះ (២.៥-៣ ខែ)

កូនពពែគួរតែទទួលទឹកដោះពីមេរបស់វាឱ្យបានច្រើន

កូនពពែដែលកើតមកមានសុខភាពល្អអាចឈរដោយខ្លួនឯងបានយ៉ាងឆាប់រហ័ស និងរកដោះមេវាឃើញដោយខ្លួនឯង បើមិនដូច្នោះទេគេអាចជួយវា។ ទឹកដោះរបស់មេពពែក្នុងរយៈពេល ៣ ថ្ងៃដំបូង (ទឹកដោះព្រៃ) មានសារៈសំខាន់ណាស់សំរាប់សុខភាព និងការលូតលាស់របស់កូនពពែ។ ទឹកដោះនេះ

សំបូរទៅដោយ **អង្គទីគ័រ** ដែលការពារកូនពពែប្រឆាំងនឹងជំងឺផ្សេងៗ រហូតដល់កូនពពែបង្កើតអង្គទីគ័រដោយខ្លួនឯងបាន ។



**រូបភាពទី ១៧: កូនពពែក្នុងពេលបៅដោះ**

បន្ទាប់ពីយ៉ាប់យ៉ឺនដោយសារផើម និងការបង្កើតកូន មេពពែត្រូវការស្ងប់ស្ងៀម: ដើម្បីឱ្យមេពពែឆាប់ស្រួលខ្លួនឡើងវិញ និងផលិតទឹកដោះបានច្រើន គេត្រូវតែ

- ថែរក្សាមេពពែក្នុងក្រោលក្នុងកំឡុង ៣ សប្តាហ៍ដំបូង បន្ទាប់ពីកើតកូនរួច
- ផ្តល់ចំណីបៃតង (ស្លឹកដំឡូង កន្ទំថេត ស្លឹកអំពិលទឹក ។ល។)
- ផ្តល់ចំណីផ្សំ (concentrates) ៤០០ ក្រាម/ថ្ងៃ
- ផ្តល់ទឹកស្អាតជាប្រចាំ
- ផ្តល់ថ្មខនិជ (សារធាតុរ៉ែ) ឱ្យពពែលិត (ជាប្រភេទចំណីសំរាប់សត្វលិតដែលគេផលិតដើម្បីផ្តល់សារធាតុរ៉ែ ដូចជា កាល់ស្យូម ហ្វូសហ្វ័រ សូដ្យូម ។ល។)

## ៦.៤. ការផ្តល់ចំណីឱ្យកូនពពែដោយដប

ថ្វីបើការផ្តល់ចំណី និងថែរក្សាមេបានល្អ ប៉ុន្តែវាអាចផលិតទឹកដោះមិនគ្រប់គ្រាន់សំរាប់កូនរបស់វា ករណីនេះកើតមានជាញឹកញាប់ចំពោះពពែដែលមានកូនភ្លោះ ឬកូនម្តង ៣ ។

របៀបដែលជំនះលើការខ្វះទឹកដោះ:

- រកមេដោះផ្សេងដែលផលិតទឹកដោះគ្រប់គ្រាន់សំរាប់ចិញ្ចឹមកូនលើសពី ១
- រឹតទឹកដោះពពែដោយដៃ រួចច្រកដបយកទៅឱ្យកូនពពែបៅ

- គេអាចយកទឹកដោះគោច្រកដបឱ្យកូនពពៃបៅ ឬផ្សំពីម្សៅទឹកដោះគោ (ដូចដែលគេផ្សំសំរាប់ឱ្យកូនក្មេងបៅ)

ចំពោះដបដែលយកមកប្រើសំរាប់កូនពពៃបៅត្រូវមានវិធានការដូចខាងក្រោមៈ

- ជានិច្ចកាលសំអាតដប និងក្បាលដោះ
- ផ្តល់ទឹកដោះឱ្យវាទៀងទាត់
- ត្រូវមានតារាងផ្តល់ចំណីត្រឹមត្រូវនិងទៀងទាត់ (មើលទំព័របន្ទាប់)
- ជៀសវាងការផ្តល់ចំណីច្រើនលើសលប់
- កូនពពៃដែលផ្តល់ទឹកដោះដោយដបត្រូវផ្តាច់ដោះដោយរូសរាន់បន្ទាប់ពី ៦ សប្តាហ៍ បន្ទាប់មកផ្តល់ចំណីបៃតងឱ្យវាស៊ី។

## ៦.៥. តារាងនៃការផ្តល់ចំណីសំរាប់កូនពពៃ

ចាប់ពីសប្តាហ៍ទី ៤ មកការផ្តល់ទឹកដោះតែមួយមុខមិនគ្រប់គ្រាន់សំរាប់តំរូវការរបស់កូនពពៃឡើយ អ្នកត្រូវផ្តល់ចំណីបន្ថែមៈ

- ដំបូងចំនួនតិច បន្ទាប់មកបង្កើនបរិមាណបន្តិចម្តងៗ នូវស្លឹកបៃតងស្រស់/ស្មៅ
- ចំណីផ្សំ ៥០ ក្រាម/ថ្ងៃ
- ផ្តល់ទឹកស្អាតជាប្រចាំ
- ផ្តល់ថ្មខនិជ (សារធាតុរ៉ែ) ឱ្យកូនពពៃលិត

**តារាងទី ២: តារាងនៃការផ្តល់ចំណី - ការផ្តល់ចំណីដោយដបដល់កូនពពែ**

| អាយុ | របបអាហារដែលផ្តល់ប្រចាំថ្ងៃ | ទឹកដោះ/១ពេល (មីលីលីត្រ) | ទឹកដោះ/១ថ្ងៃ (មីលីលីត្រ) | កំណត់សំគាល់ |
|---|---|---|---|---|
| ថ្ងៃទី ១ | ៤ ដង | ៥០ | ២០០ | រាល់ពេលឱ្យចំណីគួរផ្តល់បន្ថែមៈ |
| ថ្ងៃទី ២ | ៤ ដង | ៧៥ | ៣០០ | - ២-៣ តំណក់ខ្លាញ់ត្រី |
| ថ្ងៃទី ៣ | ៤ ដង | ១០០ | ៤៤០ | - ជាតិផ្អែម ១ ស្លាបព្រាកាហ្វេ |
| | | | | - ស៊ុត (ពិណស) ១ ស្លាបព្រាកាហ្វេ |
| ថ្ងៃទី ៤-៧ | ៤ ដង | ១៥០ | ៦០០ | |
| សប្តាហ៍ទី ២ | ៤ ដង | ២០០ | ៨០០ | ថ្មជី (សារធាតុរ៉ែ) និង ទឹកស្អាត |
| សប្តាហ៍ទី ៣ | ៣ ដង | ២៥០ | ៧៥០ | |
| សប្តាហ៍ទី ៤ | ៣ ដង | ២៥០ | ៧៥០ | ចាប់ផ្តើមឱ្យស៊ីលើវាលស្មៅ រយៈពេលខ្លះ; ចំណីបៃតងស្រស់ |
| សប្តាហ៍ទី ៥ | ២ ដង | ២០០ | ៤០០ | |
| សប្តាហ៍ទី ៦ | ២ ដង | ១៥០ | ៣០០ | កើនឡើង |

ចាប់ពី ១ ខែឡើងទៅកូនពពែអនុញ្ញាតិឱ្យស៊ីលើវាលស្មៅជាមួយមេវា លើកដំបូងក្នុងរយៈពេល ខ្លីៈ

- ២ ម៉ោងក្នុង ១ ថ្ងៃ និងនៅលើវាលស្មៅជិតៗ
- រយៈពេលឱ្យស៊ីលើវាលស្មៅគឺបន្ទាប់មកកើនឡើងបន្តិចម្តងៗរហូតដល់កូនពពែមានអាយុ ៣ ខែ

កូនពពែដែលមិនចង់ទុកពូជត្រូវក្រៀវក្នុងអាយុពី ២-៤ សប្តាហ៍។ កូនពពែទាំងអស់ត្រូវចាក់ថ្នាំការពារជំងឺកុកស៊ីដ្យូស៊ីស (coccidiosis) នៅអាយុ ៥ សប្តាហ៍ និងទំលាក់ព្រូនជាលើកដំបូងក្នុងកំឡុងពេលអាយុ ២ ខែ។ កុកស៊ីដ្យូស៊ីស ជាជំងឺរាគមួយប្រភេទដែលកើតមានជាញឹកញាប់ចំពោះកូនពពែ និងពពែជំទង់។

បន្ទាប់ពី ២.៥-៣ ខែ មេពពែផលិតទឹកដោះតិច វាស្ថិតនៅក្នុងការរកឈ្មោលទៀត ហើយនឹងចាប់ផ្តើមក្នុងវេលាជាថ្មី។ កូនពពែត្រូវបានផ្តាច់ដោះ និងមិនត្រូវការទឹកដោះមេរបស់វាទៀតទេ។ កូនពពែត្រូវបានបញ្ចូលទៅក្នុងហ្វូង និងផ្តល់ចំណីឱ្យវាជាមួយពពែដទៃទៀត។

## ៧. ការគ្រប់គ្រង និងការផ្តល់ចំណី

ពពែជាសត្វទាមទារការថែទាំល្អ និងការផ្តល់ចំណីត្រឹមត្រូវ។ ចំពោះផលិតកម្ម និងការផ្តល់ផលខ្ពស់គឺទាមទារការកែលំអនូវការផ្តល់ចំណី និងការគ្រប់គ្រង។ បង្កើនផលិតផលគឺផ្តល់ឱកាសឱ្យអ្នកចិញ្ចឹមពពែលក់សត្វបានច្រើនក្នុង ១ ឆ្នាំ។

### ៧.១. របៀបគ្រប់គ្រង ៣ យ៉ាង និងប្រព័ន្ធនៃការផ្តល់ចំណី

### ៧.១.១. ប្រព័ន្ធនៃការផ្តល់ចំណីក្នុងទ្រុង

ប្រព័ន្ធនេះភាគច្រើនអនុវត្តក្នុងតំបន់សើម និងក្នុងតំបន់ដែលមិនបង្កលក្ខណៈងាយស្រួលដល់ការឃ្វាលពពែលើវាលស្មៅ។

**ប្រភពចំណី ការផ្តល់ចំណី និងការគ្រប់គ្រងហ្វូងពពែ**

ចំណីសំរាប់ពពែបានមកពីៈ

- រុក្ខជាតិ ឬស្មៅ (ច្រូតឱ្យវាស៊ី)
- ស្លឹកឈើ គម្ពោតព្រៃ ឬចំណីបៃតងដែលកសិករដាំដោយខ្លួនឯង
- កាកសំណល់ដែលបានមកពីផលិតផលកសិកម្ម ឬកាកសំណល់ផ្ទះបាយ
- ចំណីឧស្សាហកម្ម (ចំណីផ្សំ)

ពពែត្រូវតែថែរក្សានៅក្នុងទ្រុង ។ ចំណីបៃតងត្រូវរកនៅពេលថ្ងៃ និងផ្តល់ឱ្យពពែស៊ីស្រស់ យ៉ាងតិចត្រូវផ្តល់ឱ្យវាស៊ី ៣ ពេលក្នុង ១ ថ្ងៃៈ

- ◆ ពេលព្រឹកគឺត្រូវផ្តល់បរិមាណមធ្យម
- ◆ ពេលរសៀលគឺត្រូវផ្តល់បរិមាណតិច
- ◆ រសៀលរាងជ្រេរបន្តិច/ល្ងាចជាពេលសំខាន់ក្នុងការផ្តល់ចំណី

ទឹកស្អាត និងថ្មខនិជសំរាប់សត្វលិត (សារធាតុរ៉ែ) ឬអំបិល ត្រូវដាក់ឱ្យពពែជាប្រចាំ។

ការថែរក្សាសុខភាពសត្វមានសារៈសំខាន់ណាស់ៈ

- ទ្រុងជានិច្ចកាលត្រូវតែស្អាត និងស្ងួតជានិច្ច
- ហ្វូងពពែទាំងមូលត្រូវទំលាក់ព្រូនឱ្យបានទៀងទាត់ (រាល់ ៣ ខែម្តង)
- ពិនិត្យប៉ារ៉ាស៊ីតខាងក្រៅឱ្យបានខ្ជាប់ខ្ជួន
- ត្រួតពិនិត្យក្រចកឱ្យបានញឹកញាប់

### ៧.១.២. ប្រព័ន្ធនៃការផ្តល់ចំណីដោយចង

ប្រព័ន្ធនេះពិសេសសំរាប់ទីចំណោត ឬទីជំរាល ឬក៏ជាតំបន់ដែលសំបូរទៅដោយការប្រកបដំណាំស្រូវ បន្លែ និងដំណាំផ្សេងៗ។ល។

ក្នុងលក្ខណៈបែបនេះកំណត់ឱ្យអ្នកចិញ្ចឹមពពែចង ឬកំណត់ទីតាំងឱ្យវាស៊ីលើវាលស្មៅ។

## ប្រភពនៃចំណី ការផ្តល់ចំណី និងការគ្រប់គ្រងហ្វូងពពែ

ការប៉ាន់ប្រមាណរហូតដល់ ៤០-៥០% នៃតំរូវការចំណីប្រចាំថ្ងៃអាចត្រូវផ្តល់ដោយការចិញ្ចឹមចងសំរាប់ធ្វើឱ្យមានលំនឹងត្រូវផ្តល់ស្មៅស្ងួត ចំបើង និងផ្តល់ចំណីឱ្យស៊ីក្នុងក្រោលបន្ថែមទៀតក្នុងបរិមាណតិចតួច។ ហ្វូងពពែត្រូវបានថែរក្សាក្នុងទ្រុងនៅពេលយប់។ ជាទូទៅការផ្តល់ចំណីក្នុងទ្រុងបន្ថែមជាការចាំបាច់។ ក្នុងកំឡុងពេលរដូវភ្លៀងហ្វូងពពែត្រូវតែផ្តល់ចំណីឱ្យវាស៊ីនៅក្នុងទ្រុង។

ក្នុងករណីចិញ្ចឹមចង ឬកំណត់ឱ្យស៊ីលើវាលស្មៅពាក់កណ្តាលថ្ងៃ ទាមទារការផ្តល់ចំណីបែតងបន្ថែមនៅពេលរសៀល។ ទឹកស្អាត និងថ្មខនិជ (សារធាតុរ៉ែ) ឬអំបិល សំរាប់សត្វលិត ត្រូវដាក់ឱ្យវាគ្រប់ពេលវេលា។ ការថែទាំសុខភាពសត្វមានសារៈសំខាន់ណាស់ក្នុងកំឡុងពេលរដូវភ្លៀង និងក្នុងការផ្តល់ចំណីក្នុងទ្រុង។

### ៧.១.៣. ប្រព័ន្ធនៃការចិញ្ចឹមលែងឱ្យស៊ីលើវាលស្មៅ

ប្រព័ន្ធនេះមានសារៈសំខាន់បំផុត និងរាលដាលនៅតំបន់ខ្ពង់រាប និងតំបន់ដែលមិនសំបូរដំណាំស្រូវ។ ក្នុងករណីនេះអនុញ្ញាតិឱ្យចិញ្ចឹមលែង លើវាលស្មៅពេញ ១ ថ្ងៃ និងត្រូវបានអនុវត្តន៍ច្រើន។

## ប្រភពនៃចំណី ការផ្តល់ចំណី និងការគ្រប់គ្រងហ្វូងពពែ

ជាធម្មតាហ្វូងពពែត្រូវបានបញ្ចេញពីទ្រុងនៅពេលព្រឹក និងកៀងបញ្ចូលទ្រុងវិញនៅពេលរសៀលជ្រេរ/ល្ងាច។ ហ្វូងពពែត្រូវបានថែរក្សាក្នុងទ្រុងនៅពេលយប់ និងក្នុងកំឡុងពេលរដូវភ្លៀង។ ថ្វីបើការលែងឱ្យស៊ីលើវាលស្មៅពេញ ១ ថ្ងៃក៏ដោយ តែវាអាចបំពេញតំរូវការរបស់ហ្វូងពពែប្រហែលតែ ៦០-៧០% នៃតំរូវការប្រចាំថ្ងៃរបស់វាសំរាប់ការលូតលាស់។ ជានិច្ចកាលចាំបាច់ត្រូវផ្តល់ចំណីក្នុងទ្រុងបន្ថែមដូចជា ស្លឹករុក្ខជាតិ ស្មៅ កាកសំណល់បានមកពីផលិតផលកសិកម្ម ឬកាកសំណល់ផ្ទះបាយ ឬក៏ចំណីផ្សំ។ល។

- ក្នុងករណីឱ្យពពែស៊ីតែពាក់កណ្ដាលថ្ងៃនៅលើវាលស្មៅ ត្រូវផ្ដល់ចំណីបៃតងបន្ថែមឱ្យវាស៊ីច្រើនដងនៅពេលរសៀល បន្ទាប់ពីបញ្ចូលទ្រុងរួច
- ក្នុងករណីពពែស៊ីពេញ ១ ថ្ងៃលើវាលស្មៅ គេអាចផ្ដល់ចំណីឱ្យវាស៊ីក្នុងទ្រុង ១ ថ្ងៃម្ដងនៅពេលល្ងាច

ត្រូវដាក់ទឹកស្អាត និងថ្មខនិជ (សារធាតុរ៉ែ) ឬអំបិល ឱ្យសត្វលិតគ្រប់ពេលវេលា។ ការថែទាំសុខភាពរបស់សត្វមានសារៈសំខាន់ណាស់ក្នុងកំឡុងពេលរដូវភ្លៀង និងក្នុងការផ្ដល់ចំណីក្នុងទ្រុង។



**រូបភាពទី ១៨: ការលែងពពែឱ្យស៊ីលើវាលស្មៅ និងតាមគម្ពោតព្រៃ**

## ៧.១.៤. ទំលាប់របស់សត្វពពែក្នុងការស៊ីចំណី

ទំលាប់របស់វាគឺរើសរើសអើងនូវរសជាតិចំណី វាត្រូវការចំណីស្អាត ជាសត្វខ្ជះខ្ជាយ ហើយមិនចូលចិត្តស៊ីចំណីដែលធ្លាក់នៅខាងក្រោម។ ពពែចូលចិត្តអាហារលាយបញ្ចូលគ្នាដូចជា:

- ស្លឹកឈើ ស្លឹករុក្ខជាតិពពួកកួរ និងស្មៅ
- កាកសំណល់ផ្ទះបាយបានមកពីធញ្ញជាតិ ផ្លែឈើ និងបន្លែ
- អនុផលកសិកម្មផ្សេងៗ

ពពែជាសត្វមិនចូលចិត្តចំណីកខ្វក់ ក្លិនស្អុយ សើម ឬចំណីដែលជាន់ឈ្លីពីលើ។ បើយើងដាក់ចំណីឱ្យវាច្រើនក្នុងពេលតែមួយ វាធ្វើឱ្យខ្ជះខ្ជាយ និងសល់ច្រើន។ ចំណីត្រូវតែស្អាត ស្រស់ និងស្ងួត។ ចំណីត្រូវដាក់ក្នុងទ្រុង ឬធ្នើរ ដែលត្រូវថែរក្សាឱ្យស្អាតជានិច្ច។ គេអាចចងព្យួរ មែកធាង ស្លឹកឈើ ឱ្យពពែស៊ី។ គួរផ្ដល់ចំណីឱ្យពពែ ពី ២-៣ ដង ក្នុង ១ ថ្ងៃ នូវបរិមាណតិចទើបប្រសើរ ដើម្បីជៀសវាងនូវការខ្ជះខ្ជាយចំណី។

## ៨. ប្រភេទចំណី និងប្រភពចំណី

ការផ្តល់ចំណី និងការគ្រប់គ្រងអាស្រ័យលើៈ

- ទីធ្លាសមស្របសំរាប់ចិញ្ចឹមពពែលែងឱ្យស៊ីលើវាលស្មៅ ឬសំរាប់ចិញ្ចឹមចង
- ទីធ្លាសំរាប់ផលិតស្មៅស្ងួត ឬចំបើង ឬការផ្តល់ចំណីដែលបានមកពីអនុផលកសិកម្ម
- សារៈសំខាន់នៃទីធ្លាក្នុងការចិញ្ចឹមពពែជាប្រភពមួយនៃប្រាក់ចំណូល

### ៨.១. ការលែងឱ្យស៊ីលើវាលស្មៅ

ការលែងឱ្យស៊ីលើវាលស្មៅ (និងចង) មានសារៈប្រយោជន៏ជាមូលដ្ឋាន ៤ៈ

- ប្រើប្រាស់រុក្ខជាតិពីធម្មជាតិ (natural vegetation)
- ផ្តល់របបចំណីច្រើនមុខ និងធ្វើឱ្យមានតុល្យភាព
- ផ្តល់ចំណីដល់សត្វដោយពុំមានចំណាយពីអ្នកចិញ្ចឹម
- ជាការងារតិចតួចដែលអាចធ្វើដោយមនុស្សចាស់ ឬកូនក្មេង

ក៏ប៉ុន្តែវាលស្មៅត្រូវបានប្រើប្រាស់អាស្រ័យទៅតាមរុក្ខជាតិ (their vegetation) និងលំនឹងរបស់បរិស្ថាន (ecological stability) ។

មិនត្រូវលែងឱ្យស៊ីលើវាលស្មៅក្នុងករណីៈ

- រុក្ខជាតិដុះរ៉ុយៗ
- វាលស្មៅជម្រាល
- ក្នុងកំឡុងពេលភ្លៀង
- ក្នុងកំឡុងពេលប្រមូលផលដំណាំ

ការចង ឬការកំណត់ព្រំដែនឱ្យស៊ីលើវាលស្មៅអាចប្រព្រឹត្តទៅនៅកន្លែងដែលមានរុក្ខជាតិជាមធ្យម ។

### ៨.២. ការកំណត់ព្រំដែនឱ្យស៊ីលើវាលស្មៅ

សារៈប្រយោជន៏ៈ

- ការពារវាលស្មៅពីការប្រើប្រាស់ហួសកំណត់
- ផ្តល់ឱកាស និងការលូតលាស់ឡើងវិញរបស់រុក្ខជាតិ
- ធ្វើឱ្យការប្រើប្រាស់វាលស្មៅមានការិតអតិបរមា និងប្រើប្រាស់បានយូរ

## ការឱ្យស៊ីលើវាលស្មៅអាចត្រូវបានត្រួតពិនិត្យដោយ

- អ្នកគង្វាលពពែ (កំណត់បរិវេណ)
- រយៈពេលប៉ុន្មានម៉ោង/ថ្ងៃ (កំណត់រយៈពេល)
- ចំនួនហ្វូងពពែលើវាលស្មៅ (កំណត់ចំនួនសត្វ)
- ចង ឬមានរបងព័ទ្ធជុំវិញ (កំណត់បរិវេណ)

ការចិញ្ចឹមពពែចងលើវាលស្មៅត្រូវបានអនុវត្តចំពោះហ្វូងសត្វដែលមានចំនួនតិច ។ ទីធ្លាសំរាប់ការចិញ្ចឹមចងត្រូវមានផ្តល់នូវម្លប់ និងត្រូវជ្រើសរើសកន្លែងដែលសំបូរទៅដោយរុក្ខជាតិបៃតង ដូចជាស្មៅ និង ស្លឹករុក្ខជាតិផ្សេងៗ ។ ចំពោះការចងឱ្យស៊ីលើវាលស្មៅពាក់កណ្តាលថ្ងៃគួរប្រើខ្សែប្រវែងពី ៣-៥ ម៉ែត្រ ហើយចំពោះការចងពពែឱ្យស៊ីពេញ ១ ថ្ងៃចាំបាច់ត្រូវផ្លាស់ប្តូរស្នឹងនៅពេលថ្ងៃត្រង់ ។




**រូបភាពទី ១៩: ការកំណត់ចងពពែឱ្យស៊ីលើវាលស្មៅ**

## ការគ្រប់គ្រងការលែងឱ្យស៊ីលើវាលស្មៅ

- កំណត់ឱ្យស៊ីលើវាលស្មៅអាស្រ័យទៅលើរុក្ខជាតិ និងបរិស្ថាន
- អនុញ្ញាតិឱ្យស៊ីលើវាលស្មៅអតិបរិមាពី ៨-៩ ម៉ោង
- ឱ្យពពែស៊ីលើវាលស្មៅនៅពេលស្ងួត
- បញ្ចេញហ្វូងពពែឱ្យស៊ីលើវាលស្មៅក្រោយពីស្ងួតទឹកសន្សើម (បន្ទាប់ពីម៉ោង ៧-៨ ព្រឹក)

- ជៀសវាងការបំផ្លាញដំណាំផ្សេងៗ
- ជៀសវាងការឱ្យស៊ីលើវាលស្មៅជាមួយហ្វូងគោ
- បន្ទាប់ពីការផ្តល់ចំណីក្នុងក្រោលអស់ពេលជាយូរ ត្រូវកំណត់ពេលក្នុងការលែងឱ្យស៊ីស្មៅ។ លើកដំបូងត្រូវឱ្យវាស៊ីរយៈពេលខ្លីរួចបង្កើនពេលបន្តិចម្តងៗ
- កូនពពែចាប់ផ្តើមឱ្យស៊ីលើវាលស្មៅជាលើកដំបូងក្នុងអាយុ ១ ខែ

- មិនត្រូវលែងពពែឱ្យស៊ីលើវាលស្មៅនៅរដូវភ្លៀង នៅពេលរុក្ខជាតិដុះរ៉ុយៗ និងនៅលើទីជម្រាល
- មិនត្រូវលែងពពែឱ្យស៊ីលើវាលស្មៅសើម
- មិនត្រូវលែងពពែឱ្យស៊ីយូរលើវាលស្មៅខ្ចី ដែលសំបូរដើមឈើមានស្លឹកខ្ចី ឬសំបូររុក្ខជាតិពពួកកួរ ឧទាហរណ៍ កន្ទំថេត អង្គារដី ។ល។ (ធ្វើឱ្យពពែហើមពោះ)
- មិនត្រូវឱ្យមេពពែដើរស៊ីលើវាលស្មៅក្នុងកំឡុងពេលដើម ២ សប្តាហ៍ចុងក្រោយ និងក្នុងកំឡុងពេល ៣ សប្តាហ៍ដំបូងបន្ទាប់ពីកើតកូនរួច

## ៨.៣. ចំណីបៃតង

ជាទូទៅចំណីបៃតងចាំបាច់ក្នុងការផ្តល់ចំណីបន្ថែមក្នុងទ្រុង។ ពពែចូលចិត្តស៊ីស្លឹកឈើ ដែលជាចំណីមានតំលៃ និងសំបូរទៅដោយសារធាតុចិញ្ចឹមខ្ពស់ ជាពិសេសសំបូរទៅដោយប្រូតេអ៊ីន (ជាតិសាច់) និងសារធាតុខនិជ (កាល់ស្យូម)។ វាជាការងាយស្រួលក្នុងការដាំដើមឈើតូចៗនៅតាមរបង ឬនៅក្នុងសួនច្បារសំរាប់ធ្វើជាចំណីសត្វ។

**ការបង្កើត និងការប្រើប្រាស់ដើមឈើជាចំណីសត្វ**

- ◆ ដើមកន្ទំថេត (Leucaena leucocephala)
- ◆ ស្នោគោក (Gliricidia maculata)
- ◆ រលួស (Erythrina indica)

} ជាពិសេសស្លឹករបស់វាលូតលាស់យ៉ាងឆាប់រហ័ស ហើយវាជាដើមឈើពហុប្រយោជន៍ ដែលផ្តល់ជាចំណីសត្វយ៉ាងប្រសើរ។

ក្រៅពីផ្តល់ចំណីដល់ពពែដើមឈើទាំងនេះ ក៏មានផលប្រយោជន៍ជាច្រើនទៀតដែរ ដូចជា:

- ការពារទប់ទល់ខ្យល់
- បង្កើនជាតិអាហារូតដល់ដី

- ផ្តល់ម្លប់ និងជាដើមឈើដែលជួយដល់ប្រភេទរុក្ខជាតិ តែ កាហ្វេ ដើមចន្ទន៍ កាកាវ និងម្រេច
- សំរាប់ធ្វើអុសដុត សង់ផ្ទះ និងធ្វើជាសំភារៈផ្សេងៗ
- សំរាប់ជាអាហាររបស់មនុស្ស ( ស្លឹក និងផ្លែ)
- ធ្វើជាថ្នាំដ៏មានតំលៃ
- ផ្តល់ប្រូតេអ៊ីនខ្ពស់ ( ជាតិសាច់) សំរាប់ជាចំណីសត្វ

ស្លឹករុក្ខជាតិផ្សេងទៀតដែលពពែចូលចិត្តស៊ី ហើយដែលកសិករយើងងាយរកបាន និងមិនចំណាយថវិកា ដូចជា ស្លឹកដំឡូង (ដំឡូងឈើ ដំឡូងជ្វា) បន្ទាយូន ពុទ្រា ស្លឹកអំពិលទឹក ស្លឹកអង្គារដី ស្លឹកគរ ស្លឹកអញ្ចាញ ស្លឹកថ្លើមអណ្តើក ។ល ។

**ដើមកន្ទំថេត និងដើមស្នោគោកជាចំណីពពែ**

ដើមកន្ទំថេតចាក់ឫសជ្រៅមាំទៅក្នុងដីអាចធន់នឹងអាកាសធាតុរាំងស្ងួតបានយូរ ហើយអាចផ្តល់ជាចំណីបៃតងដល់សត្វពពែនៅពេលខ្វះខាតចំណី ។ ដើមកន្ទំថេតអាចដុះលើដីដែលពុំសូវសំបូរជីវជាតិដែលរុក្ខជាតិដទៃទៀតមិនអាចដុះបាន ។ ក្នុងរយៈពេលពី ៤-៥ ខែ គេអាចប្រមូលផលវាជាលើកទីមួយ ។




***រូបភាពទី ២០: ស្លឹក និងដើមកន្ទំថេតសំរាប់ជាចំណីពពែ***

ស្នោគោកអាចដាំបាននៅតំបន់ស្ងួត និងតំបន់សើម គេប្រមូលផលជាលើកទីមួយក្នុងរយៈពេលប្រហែល ៩ ខែ ។ គេត្រូវការស្លឹក និងមែកចុងខាងចុងជាចំណីពពែ ។ មានរុក្ខជាតិផ្សេងទៀតដែលស្លឹករបស់វាមានប្រយោជន៍សំរាប់ជាចំណីពពែដូចជា រលួស ជ្រៃ ខ្នុរ ។ល ។

## ស្លឹកដំឡូងមី

ស្លឹកដំឡូងមីជាចំណីដ៏មានតម្លៃសំរាប់ពពែ វាជាចំណីដែលសំបូរទៅដោយប្រូតេអ៊ីន (ជាតិសាច់) ហើយដែលពពែចូលចិត្តស៊ី កសិករច្រើនដាក់ឱ្យសត្វស៊ីស្រស់។ គួរប្រុងប្រយ័ត្នផងដែរថាស្លឹកដំឡូងមាន ជាតិពុល (អាស៊ីតអ៊ីដ្រូស្យានីត និងតានីន) ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់របស់សត្វ។ គេអាចប្រើវិធីមួយចំនួនដើម្បីកាត់បន្ថយជាតិពុលក្នុងស្លឹកដំឡូងស្រស់ ដូចជា ការស្ងោរ ការហាល និង ផ្អាប់ ។ល។

នៅពេលដែលសត្វស៊ីស្លឹកដំឡូងមីច្រើនជ្រុល អាចធ្វើឱ្យស្លាប់ ការស្លាប់នេះបណ្តាលមកពីស្ទះនូវការធ្វើអុកស៊ីតកម្មនៃចង្វាក់ដង្ហើម (បណ្តាលមកពី អាស៊ីតអ៊ីដ្រូស្យានីត)។ ជាតិពុលនេះមានឥទ្ធិពលទៅលើការបន្តពូជរបស់សត្វ និងបន្ថយការលូតលាស់របស់វា។

ការហាលថ្ងៃជាវិធីមួយងាយស្រួលក្នុងការកាត់បន្ថយសារធាតុ ស្យានីត និងតានីន រហូតដល់ ៩០ ភាគរយ។ មុនដាក់ហាលថ្ងៃគេចិញ្ច្រាំស្លឹកដំឡូង រួចធ្វើឱ្យវាស្រពោន សារធាតុស្យានីតបានត្រូវកាត់បន្ថយដល់ កំរិតមួយដែលមានសុវត្ថិភាពដល់សត្វ។



**រូបភាពទី ២១: ស្លឹកដំឡូងមីជាចំណីពពែ**

## សួនដំណាំស្មៅ និងពពួករុក្ខជាតិកួរ

សំរាប់ផ្តល់ចំណីក្នុងទ្រុងដល់សត្វពពែគេអាចដាំស្មៅ និងពពួករុក្ខជាតិកួរក្នុងសួនដំណាំ។ ពពួករុក្ខជាតិកួរសំបូរទៅដោយប្រូតេអ៊ីន (ជាតិសាច់)។ គេអាចបង្កើនស្មៅ និងពពួករុក្ខជាតិកួរៈ

- ក្រោមដំណាំហូបផ្លែ ដើមឈើ ឬក្នុងចំការធំៗ
- នៅតាមទីវាល

វិធានការសំរាប់ការផ្តល់ចំណីបៃតង:

- ត្រូវផ្តល់ចំណីស្ងួត ហើយស្អាត
- ច្រូតចំណីបៃតង និងស្លឹកឈើក្នុងក៏រិតអាយុមធ្យមៈ ស្មៅ និងស្លឹករុក្ខជាតិផ្សេងទៀតមិនត្រូវឱ្យខ្ចីពេក ឬចាស់ពេកទេ
- ការផ្តល់ស្លឹកកន្ទំថេតឱ្យពពែស៊ីត្រូវមានកំណត់ មិនត្រូវឱ្យលើសពីមួយភាគបី (១/៣) នៃចំណីដែលវាស៊ីក្នុង ១ ថ្ងៃនោះទេ ដើម្បីជៀសវាងនូវការពុល។ ចំពោះពពែដែលមានទំងន់ ៣០ គីឡូក្រាម ត្រូវផ្តល់ស្លឹកក្នុងបរិមាណប្រហែល ១-១.៥ គីឡូក្រាម។
- ជៀសវាងការផ្តល់ពពួករុក្ខជាតិក្ដួរស្រស់លើសលប់។ ក្នុងការផ្តល់ចំណីពពួករុក្ខជាតិក្ដួរទាមទារនូវតុល្យភាពជាមួយប្រភេទចំណីផ្សេងទៀតដែលសំបូរជាតិសរសៃជាង ដូចជា ស្មៅមួយចំនួន ស្មៅស្ងួត ឬចំបើង។

## ៨.៤. ចំណីដែលបានមកពីកាកសំណល់ផ្ទះបាយ

កាកសំណល់ផ្ទះបាយសំបូរទៅដោយថាមពល វីតាមីន និងសារធាតុខនិជ ហើយជាចំណីបន្ថែមដ៏មានតំលៃសំរាប់សត្វពពែ។ កសិករចិញ្ចឹមពពែជាញឹកញាប់មិនបានយកចិត្តទុកដាក់ចំពោះសារធាតុចិញ្ចឹមខ្ពស់ដ៏មានតំលៃដែលមានក្នុងចំណីប្រភេទនេះទេ។ ជាពិសេសក្នុងកំឡុងពេលខ្វះខាតចំណី កាកសំណល់ ផ្ទះបាយអាចជាប្រភពចំណីដ៏សំខាន់។

### ប្រយ័ត្ន

កាកសំណល់បានមកពីផ្លែឈើ និងបន្លែផ្សេងៗដែលងាយស្អុយខូចលឿន គេត្រូវផ្តល់ចំណីទាំងនេះឱ្យពពែស៊ីភ្លាម ឬក្នុងថ្ងៃតែមួយ។ កាកសំណល់ផ្ទះបាយដែលស្អុយខូចអាចធ្វើឱ្យគ្រោះថ្នាក់ដល់សុខភាពរបស់ពពែ។

### កាកសំណល់ខ្ទិះដូង

កាកសំណល់សាច់ដូងដែលពួតយកខ្ទិះរួចសំបូរទៅដោយជាតិខ្លាញ់ និងជាតិអំបិលធម្មតា ជាចំណីមួយដែលសត្វពពែចូលចិត្តស៊ីច្រើន។ កាកសំណល់នេះគេសំងួតវា ហើយអាចរក្សាទុកពី ២-៣ ថ្ងៃ សំរាប់ផ្តល់ឱ្យវាស៊ីនៅពេលក្រោយ។

### កាកសំណល់បានមកពីបន្លែផ្សេងៗ

សំបក កំទេចកំទីបន្លែក្នុងផ្ទះបាយ ឬបន្លែហួបសល់មិនត្រូវបោះវាចោលឡើយ យើងអាចយកវាធ្វើជាចំណីសត្វពពែបាន។

### កាកសំណល់បានមកពីផ្លែឈើផ្សេងៗ

សំបកផ្លែឈើ ដូចជា សំបកចេក ស្វាយ ល្ហុង អាវ៉ូកាដូ សំបកក្រូច ម្នាស់ ។ល។ គឺជាចំណីដែលសំបូរទៅដោយសារធាតុចិញ្ចឹមខ្ពស់។ ប៉ុន្តែចំណីប្រភេទនេះឆាប់ខូច អាស្រ័យហេតុនេះគេត្រូវឱ្យពពែស៊ីភ្លាម ក្នុងរយៈពេលពី ១០-១៥ នាទី។

### កាកសំណល់បានមកពីធញ្ញជាតិ

ចំពោះចំណីអាហារសំរាប់មនុស្សត្រូវបានលាងសំអាតមុនពេលចំអិន។ បន្ទាប់ពីលាងបំណែកតូចៗ និងសំបកនៅលាយឡំជាមួយទឹក ទឹកនេះគួរផ្តល់ឱ្យពពែផឹក យើងអាចលាយវាជាមួយអំបិលបន្តិច។

## ៨.៥. ចំណីដែលបានមកពីអនុផលកសិកម្ម

អនុផលកសិកម្មមានតំលៃជាច្រើនមិនត្រូវបានយកមកប្រើប្រាស់ដោយអ្នកចិញ្ចឹមសត្វឡើយ។ អនុផលទាំងនោះមានសារៈសំខាន់ជាចំណីសត្វជាពិសេសនៅពេលកង្វះខាតចំណី។

សំណល់ពីកសិផលដែលអាចរកបានសំរាប់ជាចំណីដ៏មានតំលៃរបស់ពពែ:

- ចំបើងដែលបានមកពីរុក្ខជាតិពពួកកួរ (សណ្តែក): គេអាចសំងួតវា និងស្តុកទុកជាចំណីសត្វនៅថ្ងៃក្រោយ
- សំបកសណ្តែកផ្សេងៗ
- ដើមចេកហាន់ជាចំណិតៗលាយជាមួយសំបកធញ្ញជាតិ ឬកន្ទក់ ដែលធ្វើឱ្យសត្វចូលចិត្តស៊ី
- បន្លែដែលសល់ពីលក់
- ស្លឹកដំឡូងជ្វា ស្លឹកដំឡូងឈើ ។ល។

## ៨.៦. ចំណីផ្សំ ឬចំណីដែលមានសារធាតុចិញ្ចឹមខ្ពស់ (concentrate)

ចំណីផ្សំសំបូរទៅដោយថាមពល និងប្រូតេអ៊ីន ហើយមានតំលៃខ្ពស់ អាស្រ័យហេតុនេះការផ្តល់ចំណីផ្សំត្រូវមានកំណត់គឺត្រូវផ្តល់ឱ្យនៅពេលណាតំរូវការទាមទារថាមពលខ្ពស់។

ត្រូវផ្តល់ឱ្យសត្វក្នុងករណីៈ

- មេពពែ ក្នុងកំឡុងពេលចើម ១ ខែចុងក្រោយ (៤០០ក្រាម/ថ្ងៃ)
  ក្នុងកំឡុងពេល ២ ខែដំបូងបន្ទាប់ពីកើតកូនរួច (៤០០ក្រាម/ថ្ងៃ)
  ក្នុងកំឡុងពេល ៣ ខែដំបូងបន្ទាប់ពីកើតកូនរួច (២០០ក្រាម/ថ្ងៃ)
- កូនពពែតូចត្រូវការលូតលាស់ឆាប់ចាប់ពីអាយុ ៣ សប្តាហ៍រហូតដល់ផ្តាច់ដោះ (៥០ក្រាម/ថ្ងៃ)
- ផ្តល់ឱ្យសត្វឈឺ

**ចំណីផ្សំ:**

គេអាចលាយកន្ទក់ ៦០% ជាមួយកាកដូង ៤០% (ពូតយកខ្ទិះរួច) សារធាតុផ្សំទាំង ២ នេះងាយរកបានពេញ ១ ឆ្នាំ។ កសិករអាចលាយវាបានដោយខ្លួនឯងនៅផ្ទះ ចំណីផ្សំបែបនេះមានតំលៃថោកជាងចំណីដែលគេផ្សំរួចលក់នៅលើទីផ្សារ។ ពពែចូលចិត្តចំណីផ្សំពីសារធាតុគ្រើម ឬពីបំណែកតូចៗ។ ចំណីដែលជាប់នៅនឹងស្នូកត្រូវសំអាតឱ្យបានហ្មត់ចត់។

## ៨.៧. សារធាតុខនិជ (សារធាតុរ៉ែ)

ការផ្តល់ចំណីមិនបានគ្រប់ជ្រុងជ្រោយអាចធ្វើឱ្យខ្វះសារធាតុខនិជដែលជះឥទ្ធិពលមិនល្អដល់មេពពែ ដល់សុខភាពវា និងដល់ផលិតកម្មពពែ។

គ្រោះថ្នាក់ចំពោះការខ្វះសារធាតុខនិជ (កាល់ស្យូម ផូស្វ័រ និងសូដ្យូម) អាចមានច្រើន។ កង្វះកាល់ស្យូម និងផូស្វ័រ ធ្វើឱ្យឆ្អឹងលូតលាស់មិនធម្មតា ធ្វើឱ្យកូនពពែ/ពពែជំទង់ ក្រិន ពន្យឺតការលូតលាស់របស់វា។ យើងអាចផ្តល់សូដ្យូមឱ្យពពែតាមរយៈអំបិល (Nacl) ការខ្វះសូដ្យូមធ្វើឱ្យសំពាធ (Osmosis) ក្នុងខ្លួនសត្វចុះទាប ជាលទ្ធផលបាត់បង់ជាតិទឹកក្នុងខ្លួនវា ធ្វើឱ្យសត្វលូតលាស់យឺត និងបន្ថយការប្រើប្រាស់ថាមពល។

**សូដ្យូមៈ**

វិធីងាយស្រួលគឺការផ្តល់សូដ្យូមតាមស្រកីដូង (ដូងទុំ) កាប់យកស្រកី ហើយបំពេញវាដោយល្បាយរាវ (សូលុយស្យុង) អំបិល បន្ទាប់មកយើងចងព្យួរវាកំពស់ប្រហែល ០.៧៥ ម៉ែត្រ។ អំបិលនឹងជ្រាបចេញពីស្រកីដូង ហើយពពែលិតស្រកីដូងនេះ។

គេអាចផ្តល់សារធាតុខនិជដល់ពពែតាមរយៈការលិតថ្មខនិជ (សារធាតុរ៉ែ)។ គេអាចលាយអំបិល៣.៥ គីឡូក្រាម ជាមួយសារធាតុរ៉ែ ១ គីឡូក្រាម រួចចងព្យួរនៅនឹងជញ្ជាំងទ្រុងដើម្បីឱ្យពពែលិត។

ការផ្តល់សារធាតុខនិជបន្ថែមជាពិសេសសំរាប់:

- ◈ មេពពែដើមជិតគ្រប់ខែក្នុងកំឡុងខែទី ៤ ឬខែទី ៥ នៅពេលនោះកូនពពែក្នុងពោះមានការវិវឌ្ឍន៍យ៉ាងលឿន
- ◈ មេពពែបំបៅកូន ដែលប្រើប្រាស់សារធាតុខនិជច្រើនសំរាប់ផលិតទឹកដោះ
- ◈ កូនពពែ និងពពែបារ័យក្មេង សំរាប់ការលូតលាស់របស់វា (ធ្មេញ និងឆ្អឹង)

## ៨.៨. កំឡុងពេលខ្វះចំណី

ការផ្តល់ចំណីមានការលំបាកជាញឹកញាប់ក្នុងរដូវប្រាំង ឬនៅពេលរាំងភ្លៀងដ៏យូរ ឬក៏ក្នុងកំឡុងពេលប្រមូលផលដែលពេលនោះពពែត្រូវបានថែរក្សាក្នុងទ្រុងដើម្បីជៀសវាងការបំផ្លាញដំណាំ។ ដើមស្នោគោក អំពិលទឹក ពុទ្រា កន្ធំថេត រលួស ស្តៅ ។ល។ ផ្តល់នូវចំណីបៃតងក្នុងរដូវក្តៅនៅពេលដែលខ្វះខាតស្មៅក្នុងកំឡុងពេលនេះ។ ចំបើងក៏ជាចំណីមួយអាចជួយដល់ពពែនៅពេលខ្វះស្មៅ ចំបើងគួរកាត់វាឱ្យខ្លីហើយលាយជាមួយរុក្ខជាតិបៃតងខ្លះ។

### អនុសាសន៍ចំពោះការខ្វះចំណី

១. បង្កើតសួនដំណាំពហុប្រយោជន៍ ដូចជា កន្ធំថេត ស្នោគោក រលួស ។ល។ ឬផ្តល់ឱ្យវានូវស្លឹកពុទ្រា ស្លឹកអំពិល.....

២. កាកសំណល់ដែលបានមកពីបន្លែ និងផ្លែឈើផ្សេងៗ

៣. ចំបើងដែលបានមកពីរុក្ខជាតិគួរ

៤. ចំបើង (rice straw) កាត់ខ្លីៗ

៥. កន្ទក់លាយកាកដូងពូតយកខ្ទិះរួច

### វិធានការនៃការផ្តល់ចំណី

- ពពែដែលផ្តល់ចំណីបានល្អនឹងលូតលាស់ឆាប់រហ័ស ហើយផលិតកូនដែលមានសុខភាពល្អបានទៀងទាត់

- ពពែដែលផ្តល់ចំណីបានល្អនឹងមិនងាយឈឺឡើយ
- ពពែដែលផ្តល់ចំណីបានល្អមិនត្រូវការបសុពេទ្យឡើយ និងមិនចាំបាច់ចំណាយថវិកាច្រើន
- ចំណីដែលផ្តល់ឱ្យពពែត្រូវស្អាត ស្រស់ និងស្ងួត
- សំអាតស្នូកចំណីឱ្យបានហ្មត់ចត់ជារៀងរាល់ថ្ងៃ
- ចាំបាច់បន្ថែមការផ្តល់ចំណីក្នុងទ្រុងឱ្យបានញឹកញាប់
- ផ្តល់របបអាហារច្រើនប្រភេទ គ្រប់មុខ និងមានតុល្យភាព ដូចជាស្មៅ និងពពួករុក្ខជាតិក្ងួរ ស្លឹកឈើ និងកាកសំណល់ផ្ទះបាយដែលសមស្រប
- ត្រួតពិនិត្យការលែងឱ្យស៊ីលើវាលស្មៅ
- ផ្តល់ចំណីបៃតង និងស្លឹកឈើបៃតង : ស្មៅ និងស្លឹករុក្ខជាតិបៃតងមិនត្រូវឱ្យខ្ចីពេក និងចាស់ពេកទេ
- ជៀសវាងការឱ្យស៊ីពពួករុក្ខជាតិក្ងួរលើសលប់។ ការផ្តល់រុក្ខជាតិក្ងួរទាមទារតុល្យភាពជាមួយប្រភេទចំណីផ្សេងទៀត ដែលមានជាតិសរសៃច្រើនជាង ដូចជាស្មៅ និងចំបើង
- ការផ្តល់ស្លឹកកន្ទំថេតឱ្យពពែស៊ីត្រូវមានកំណត់ ត្រូវផ្តល់ច្រើនបំផុតមួយភាគបី (១/៣) នៃចំណីដែលវាស៊ីប្រចាំថ្ងៃ (ស្លឹកប្រហែល ១-១.៥ គីឡូក្រាម សំរាប់ពពែទំងន់ ៣០ គីឡូក្រាម) ដើម្បីជៀសវាងនូវការពុល
- ចំណីផ្សំត្រូវផ្តល់តែចំពោះ:
  - ◆ ពពែធំ និងមេពពែបំបៅកូន
  - ◆ កូនពពែ និងពពែឈឺ
- ឱ្យពពែស៊ី ២-៣ ដង/ថ្ងៃ
- ពេលវេលានៃការផ្តល់ចំណីត្រូវទៀងទាត់
- ផ្តល់ទឹកស្អាតទៀងទាត់ និងគ្រប់ពេលវេលា
- ផ្តល់សារធាតុខនិជ ដូចជា ហ្វូស្វ័រ កាល់ស្យូម អំបិល តាមរយៈការផ្តល់ឱ្យវាលិត (ថ្មខនិជ)។

## ៩. ទឹក

ទឹកជាកត្តាសំខាន់ ១ ក្នុងការចិញ្ចឹមសត្វ ត្រូវផ្តល់ទឹកស្អាតដល់សត្វឱ្យបានគ្រប់គ្រាន់ និងគ្រប់ពេលវេលា។ ត្រូវប្តូរទឹកជារៀងរាល់ថ្ងៃ និងធុងដាក់ទឹកត្រូវស្អាតជានិច្ច។ ទឹកមានសារៈសំខាន់ណាស់ ជាពិសេសសំរាប់មេពពែបំបៅកូន និងកូនរបស់វា។

ធុងទឹក ឬស្នូកទឹកដែលដាក់ឱ្យពពែផឹក ត្រូវព្យួរត្រឹមកវា កំពស់ប្រហែល ០.៦ ម៉ែត្រ ដើម្បីធ្វើឱ្យពពែងាយស្រួលផឹក និងមិនធ្វើឱ្យទឹកកខ្វក់ (ជៀសវាងពពែជុះអាចម៍ដាក់)។ ក្នុងការលែងឱ្យស៊ីលើវាលស្មៅត្រូវប្រុងប្រយ័ត្នកុំឱ្យពពែផឹកទឹកកខ្វក់ដែលជាប្រភពចំលងមេរោគ និងជំងឺផ្សេងៗ។

## ១០. ការថែទាំពពែ

- ពពែដែលមានសុខភាពល្អអាចលូតលាស់ល្អ ផលិតកូនបានទៀងទាត់ក្នុងរយៈពេលខ្លី និងផ្តល់នូវផលិតផលបានយូរ
- ហ្វូងពពែត្រូវមានសុខភាពល្អ ដើម្បីឱ្យការចិញ្ចឹមពពែទទួលនូវកំរៃ

នៅពេលដែលកសិករចិញ្ចឹមពពែធ្វេសប្រហែស ដូចជាៈ

- ទ្រុង និងចំណីកខ្វក់ នាំឱ្យឆ្លងមេរោគ និង ជំងឺផ្សេងៗ
- ផ្តល់ចំណីមិនបានល្អ ធ្វើឱ្យពពែចុះខ្សោយ និង កូនរបស់វាខ្សោយ
- ប៉ារ៉ាស៊ីតលើស្បែក (ចៃ) នាំឱ្យកើតជំងឺ និង ធ្វើឱ្យខូចស្បែក
- ប៉ារ៉ាស៊ីតខាងក្នុង (ព្រូន) ធ្វើឱ្យលូតលាស់យឺត និង ស្រកទំងន់
- ការគ្រប់គ្រងមិនល្អ ធ្វើឱ្យផលិតផលថយចុះ និង ងាប់

ការខាតបង់ខាងលើនេះអាចជៀសវាងបានយ៉ាងពិតប្រាកដ ឬអាចកាត់បន្ថយបានដោយមានវិធានការងាយស្រួល ដែលកសិករចិញ្ចឹមពពែអាចអនុវត្តន៍ខ្លួនឯងបាន។

ការចំណាយអស់តិចបំផុត និងមានប្រសិទ្ធិភាពច្រើនក្នុងការថែរក្សាហ្វូងពពែឱ្យមានសុខភាពល្អៈ

- ធ្វើអនាម័យឱ្យបានហ្មត់ចត់បំផុត ទាំងក្នុង និងជុំវិញទ្រុងពពែ
- ត្រួតពិនិត្យពពួកប៉ារ៉ាស៊ីតខាងក្រៅ (ចៃ)
- ត្រួតពិនិត្យពពួកប៉ារ៉ាស៊ីតខាងក្នុង (ព្រូន)
- ផ្តល់ចំណីបានល្អ និងគ្រប់គ្រងបានល្អ
- ត្រួតពិនិត្យរាល់ថ្ងៃនូវហ្វូងពពែទាំងមូល
- ប្រុងប្រយ័ត្នទាន់ពេលវេលា

អ្នកចិញ្ចឹមពពែដែលមិនធ្វេសប្រហែសចំពោះការថែទាំសុខភាពរបស់ពពែ និងធ្វើតាមវិធានការនៃការអនុវត្តន៍ត្រឹមត្រូវដូចជា : ការផ្តល់ចំណី និងការលែងឱ្យស៊ីលើវាលស្មៅ មិនសូវត្រូវការបសុពេទ្យព្យាបាលប៉ុន្មានទេ។ ដូច្នេះ អាចជៀសវាងនូវការខាតបង់ និងការចំណាយដែលមិនចាំបាច់។

## ១០.១. ការថែទាំ និងធ្វើអនាម័យ

✳ ការសំអាតស្នូកទឹក និងស្នូកចំណីប្រចាំថ្ងៃ

មិនត្រូវឱ្យពពែស៊ីនូវចំណីដែលសល់ចោលទេ ចំណីទាំងនេះត្រូវតែយកចេញ និងសំអាតស្នូកឱ្យបានហ្មត់ចត់។ម្យ៉ាងទៀតចំណីដែលសល់ក្នុងស្នូកធ្វើឱ្យចំណីថ្មីស្អុយខូចចោល បើសត្វស៊ីវាបណ្តាលឱ្យខូចសុខភាព។

✳ ការបោសសំអាតទ្រុងប្រចាំថ្ងៃ

ក្នុងការបោសសំអាតចាំបាច់ណាស់ក្នុងការពិនិត្យជង្គរ។ កាកសំណល់ភាគច្រើនត្រូវបានស្រក់តាមប្រហោងរនាបទៅក្រោម កាកសំណល់ខ្លះទៀតដែលជាប់នឹងរនាបត្រូវតែសំអាតចេញ។ កន្លែងដែលពពែឈរ ច្រើនកខ្វក់ និងជាប់នូវមេរោគផ្សេងៗ ដែលចាំបាច់ត្រូវតែលាងសំអាតចេញឱ្យបានហ្មត់ចត់។

✳ ការប្រមូល និងកើបលាមកសត្វ

លាមកសត្វគួរតែប្រមូលសំរាប់ធ្វើជីកំប៉ុស្ត ឬលក់ក្នុងចន្លោះពេលដ៏ខ្លី ដើម្បីជៀសវាងការចំលងជំងឺ និងប៉ារ៉ាស៊ីត ទៅកសិដ្ឋានផ្សេងទៀត និងទៅដល់ការរស់នៅរបស់មនុស្ស។ លក្ខណៈងាយស្រួលក្នុងការរក្សាបរិវេណឱ្យស្អាត អ្នកអាចធ្វើរបងព័ទ្ធជុំវិញខាងក្រោមក្រោល។ លាមកពពែគឺជាជីដ៏ល្អ កសិករអាចរកកំរៃបានពីការលក់ជីនេះ។ ជីដែលបានមកពីលាមកពពែសំបូរទៅដោយ អាហ្សូត និងហ្វូសហ្វ័រជាងជីដែលបានមកពីលាមកគោ និងក្របី។



**រូបភាពទី ២២: ការបោសសំអាតទ្រុងប្រចាំថ្ងៃ**

## ការតំរឹមក្រចកជើងពពែ

- ការតំរឹមក្រចកជើងជាការចាំបាច់សំរាប់ការរស់នៅដ៏ស្រួលរបស់ពពែ
- ការតំរឹមក្រចកជើងមានសារៈសំខាន់សំរាប់សុខភាពសត្វ

ការតំរឹមក្រចកជើងនេះត្រូវការជាពិសេសសំរាប់ពពែដែលចិញ្ចឹម និងផ្តល់ចំណីក្នុងទ្រុង និងក្នុងកំឡុងពេលរដូវភ្លៀង។

កសិករអាចប្រើកាំបិតមុតតំរឹមក្រចកជើងពពែដោយខ្លួនគាត់ផ្ទាល់ យ៉ាងតិចបំផុតក្នុង ១ ខែម្តង ជាពិសេសក្រចកជើងពពែបាដែលទុកពូជត្រូវត្រួតពិនិត្យឱ្យបានទៀងទាត់។ កសិករដែលពុំធ្លាប់អនុវត្តន៍ដោយខ្លួនឯងពីមុនមកអាចត្រូវបានបង្ហាត់ពីអ្នកដែលមានបទពិសោធន៍ ឬ បសុពេទ្យ។

ក្រចកជើងពពែដែលលូតលាស់ហួសអាចបណ្តាលឱ្យ:

- ✱ ឈឺចាប់នៅពេលដើរ
- ✱ ធ្វើឱ្យខូចទ្រង់ទ្រាយជើង
- ✱ ឆ្លងមេរោគ (ក្រចកពិណក្រហម)
- ✱ ខូច របើកក្រចក ឬរឹងជើងពិបាកដើរ
- ✱ ចំពោះពពែបាៈ គ្មានចំណង់ពាក់មេ

ហើយជាលទ្ធផលដែលបានមកពីបញ្ហាខាងលើនេះ នាំឱ្យពពៃះ

- បន្ថយសកម្មភាពរបស់វាលើវាលស្មៅ និងបន្ថយការស៊ីចំណី
- ការផលិតទឹកដោះថយចុះ និងបន្ថយការលូតលាស់

ការតឹមក្រចកជើងបង្កលក្ខណៈងាយស្រួលនៅពេលព្រឹក ដែលនៅពេលនោះក្រចកជើងមានភាពទន់។

## ១១. ជំងឺ

នៅពេលសំគាល់ឃើញសត្វឈឺ អ្នកត្រូវតែ:

- បំបែកសត្វឈឺចេញពីហ្វូងជាបន្ទាន់
- អនុវត្តន៍នូវវិធានការ ការពារ និងព្យាបាលជំងឺ
- ករណីចាំបាច់ហៅបសុពេទ្យ

### ១១.១ ក្រចកពណ៌ក្រហម

ជំងឺក្រចកក្រហមគឺជាការឆ្លងមេរោគនៅត្រង់ក្រចក ហើយអាចបណ្តាលឱ្យសត្វរឹងជើងដើរមិនរួច។ ក្នុងករណីនេះបណ្តាលមកពី:

- ការគ្រប់គ្រងធ្វេសប្រហែស និងការតឹមក្រចកមិនបានត្រឹមត្រូវ
- លែងឱ្យស៊ីលើវាលស្មៅសើម
- ដាក់ពពៃក្នុងទ្រុងសើម

**រោគសញ្ញា:**

- ជើងឡើងហើមធំ
- រឹងជើងដើរមិនរួច ដំបូងមានលក្ខណៈតិចតួច បន្ទាប់មកកើនឡើងយ៉ាងឆាប់រហ័ស
- ក្រចកជើងមានក្លិនស្អុយ

**ការការពារ:**

- ការគ្រប់គ្រងល្អ
- ត្រួតពិនិត្យក្រចកជើង និងតឹមឱ្យបានទៀងទាត់
- កំរាលខាងក្រោមនៃទ្រុងត្រូវស្ងួត
- ជៀសវាងការលែងឱ្យស៊ីលើវាលស្មៅសើម

**ការព្យាបាលៈ**

- ចិតក្រចករហូតដល់ឃើញកន្លែងដែលឆ្លងមេរោគ
- ព្យាបាលរបួសដោយដាក់ជើងសត្វត្រាំក្នុងល្បាយថ្នាំៈ
    - ◆ ល្បាយ ១០% ទង់ដែងស៊ុលហ្វាត (copper sulphate)
    - ◆ ល្បាយ ១០% ហ្វមម៉ាលីន (formalin)
- ប្រើអង់ទីប៊ីយ៉ូទិចរុំដំបៅជាការចាំបាច់
- ត្រូវតែរុំរបួសជើង
- ត្រូវប្តូរសត្វដែលរបួសទៅកន្លែងស្ងួត
- ព្យាបាលឡើងវិញដដែលៗ រហូតទាល់តែរបួសជាសះស្បើយ

## ១១.២ ការថែទាំ ព្យាបាលមុខរបួសតូច និងបូស

ក្នុងពេលលែងឱ្យស៊ីលើវាលស្មៅ និងក្នុងទ្រុង ពពែអាចរងរបួស ដូចជា របកស្បែក ឬដំបៅ។ ការគ្រោះថ្នាក់នេះអាចបណ្តាលមកពីបន្លានៃគុម្ពោតព្រៃ ដោយជល់គ្នា ឬដោយគ្រោះថ្នាក់ផ្សេងៗ។ វាជាការសំខាន់ណាស់ដែលដឹងអំពីមុខរបួស ឬដំបៅបែបនេះទាន់ពេលវេលា។ ប្រសិនបើអ្នកមិនប្រុងប្រយ័ត្ន ដំបៅតូចនឹងក្លាយជាដំបៅធំ ហើយនឹងមានសភាពធ្ងន់ធ្ងរ។ អាស្រ័យហេតុនេះៈ

- អ្នកចិញ្ចឹមត្រូវតែប្រុងប្រយ័ត្នត្រួតពិនិត្យហ្វូងពពែរៀងរាល់ថ្ងៃ
- មុខរបួសតូច ឬធំត្រូវតែព្យាបាលជាបន្ទាន់

វិធានការសំខាន់បំផុតសំរាប់ព្យាបាលមុខរបួសៈ

- ដៃ សំភារៈផ្សេងៗសំរាប់ព្យាបាល និងសំឡី ដាច់ខាតត្រូវតែស្អាត
- មុខរបួសជើងដែលមានហូរឈាម និងបូសជើង ត្រូវការការប្រុងប្រយ័ត្ន

ជាដំបូងត្រូវកាត់សក់ ឬរោមដែលនៅជុំវិញមុខរបួស ហើយត្រូវយកកំទេចកំទី ធូលី ខ្សាច់ ដង្កូវ។ល។ ចេញពីមុខរបួស។ មុខរបួសត្រូវតែសំអាតឱ្យបានហ្មត់ចត់ដោយថ្នាំសំលាប់មេរោគ ដោយប្រើដង្កាប់ ឬ តំបៀត និងសំឡី។

បូសត្រូវទំលុះបើកមុខវាដោយប្រើកាំបិតមុត ហើយខ្ទុះត្រូវច្របាច់យកចេញឱ្យអស់ដោយថ្នមៗ។ បន្ទាប់មកមុខរបួសត្រូវលាងសំលាប់មេរោគដោយប្រើទឹកថ្នាំ និងសំឡីស្អាត។ ចុងបញ្ចប់មុខរបួសត្រូវរុំវាដោយលាប អង់ទីប៊ីយ៉ូទិច ឬតេត្រាស៊ីគ្លីន។ ការព្យាបាលនេះត្រូវធ្វើដដែលៗ ឡើងវិញជាច្រើនដង

រហូតដល់មុខរបួសជាទាំងស្រុង។ មុខរបួស ឬរបួសដែលមានសភាពធ្ងន់ធ្ងរខ្លាំងត្រូវតែព្យាបាលដោយបសុពេទ្យ។

## របួសហូរឈាម

- បង្អាក់ការហូរឈាមត្រង់មុខរបួស
- ប្រើបង់រុំមុខរបួសឱ្យតឹង
- សង្កត់លើមុខរបួស និងដាក់ទឹកកកពីលើ (ក្នុងករណីហូរឈាម)
- ក្នុងករណីចាំបាច់ហៅបសុពេទ្យឱ្យដេររបួស
- សំលាប់មេរោគ និងរុំមុខរបួសដោយប្រើម្សៅអង់ទីប៊ីយ៉ូទិច

## ពស់ចឹក

- ជាដំបូងទុកឱ្យរបួសហូរឈាម
- បន្ទាប់មកយកបង់រឹតពីលើមុខរបួសឱ្យតឹង
- បង្អាក់កុំឱ្យឈាមហូរ
- ហៅបសុពេទ្យ (បន្ទាបជាតិពិស)
- ចុងបញ្ចប់ សំលាប់មេរោគ និងរុំមុខរបួសដោយប្រើម្សៅអង់ទីប៊ីយ៉ូទិច

### ១១.៣ ប៉ារ៉ាស៊ីតខាងក្រៅ

គឺជាពពួកសត្វល្អិតដែលរស់នៅលើស្បែក ឬលើរោមរបស់ពពែ ហើយជាទូទៅច្រើនធ្វើឱ្យមានបញ្ហាដល់ហ្វូងពពែ។ ពពួកប៉ារ៉ាស៊ីតខាងក្រៅអាចបណ្តាលឱ្យខាតបង់ថវិកាច្រើនៈ

- នៅតាមស្បែកដែលរបួស ដែលអាចនាំឱ្យៈ
    - ◆ របួសធ្ងន់ធ្ងរ ឆ្លងមេរោគផ្សេងៗ
    - ◆ ធ្វើឱ្យស្បែកអន់ និងតំលៃរបស់វាថយចុះ
- តាមរយៈការបញ្ចូនឈាមប៉ារ៉ាស៊ីតបណ្តាលឱ្យពពែកើតជំងឺធ្ងន់ធ្ងរផ្សេងទៀត

ទាំងអស់នេះធ្វើឱ្យពពែស្រកទំងន់ ចុះខ្សោយទៅៗ ហើយអាចងាប់។ ប៉ារ៉ាស៊ីតខាងក្រៅអាចដឹងបានដោយងាយស្រួល ដោយទាមទារការត្រួតពិនិត្យហ្វូងសត្វឱ្យបានទៀងទាត់ ជាពិសេសក្នុងត្រចៀករបស់ពពែត្រូវពិនិត្យឱ្យបានហ្មត់ចត់ ព្រោះត្រង់កន្លែងនេះសំបូរទៅដោយចៃច្រើន។ ជួនកាលស្នាមរបួសនៅ

ចន្លោះក្រចកជើងបណ្តាលមកពីចៃ ដែលក្រោយមកធ្វើឱ្យឆ្លងមេរោគ របួសបែបនេះអាចធ្វើឱ្យពពែរឹងជើងដើរមិនរួច។

## អង្គែរ

អង្គែជាជំងឺសើរស្បែកម្យ៉ាងបណ្តាលមកពីចៃ (mites) វាធ្វើឱ្យសក់ និងស្បែកប្រែប្រួល។ ចំពោះអង្គែស្បែកវាស៊ីរូងទំលុះស្បែកហើយពងនៅទីនោះ។ ពពែមានចៃវានៅមិនស្ងៀម ស្បែកវារោលក្រហាយខ្លាំង ពីព្រោះបណ្តាលមកពីការរមាស់ ពពែត្រដុសខ្លួនវាជាញឹកញាប់ ហើយខាំស្បែករបស់វា។ រោមសត្វឡើងគ្រើម មិនស្មើ ហើយបះ ដោយមានជ្រុះរោម និងស្បែកឡើងក្រហម។ ប្រសិនបើអ្នកមិនប្រុងប្រយ័ត្នក្រោយមកនឹងធ្វើឱ្យស្បែករបស់វាស្តើង ពេលខ្លះមានស្នាមរលាត់ និងធ្វើឱ្យពពែមានការឈឺចាប់។ ពពែដែលទទួលរងនូវបញ្ហានេះធ្វើឱ្យវាស្រកទំងន់ រស់នៅក្នុងលក្ខខ័ណ្ឌដ៏លំបាក ហើយអាចបណ្តាលឱ្យវាស្លាប់ផងដែរ។

## ការការពារ និងការព្យាបាលប៉ារ៉ាស៊ីតខាងក្រៅ

ការការពារមានប្រសិទ្ធិភាពគឺចាប់ផ្តើមជាមួយការរក្សាក្រោល និងបរិវេណជុំវិញឱ្យបានស្អាតដោយពុំឱ្យមានប៉ារ៉ាស៊ីត។ ប៉ារ៉ាស៊ីត ឬចៃពងនៅតាមប្រហោងក្តារ ឬឈើដែលប្រេះ ដើម្បីជៀសវាងបញ្ហានេះ អ្នកត្រូវលាបទ្រុងពពែដោយប្រើប្រេងម៉ាស៊ីន។

វិធានការដ៏មានប្រសិទ្ធិភាពគឺប្រើប្រេងកាតលាយជាមួយទឹក (ប្រេងកាត ០.៥ លីត្រ លាយទឹក ១០ លីត្រ) បាញ់សំលាប់ប៉ារ៉ាស៊ីតខាងក្រៅ ដោយបាញ់ស្រោចទៅលើទ្រុងទាំងមូល។ ក្នុងករណីចាំបាច់ត្រូវបាញ់ឡើងវិញម្តងទៀតបន្ទាប់ពី ១ ខែ។

ក្នុងករណីជាច្រើនពពែទទួលប៉ារ៉ាស៊ីតខាងក្រៅនៅពេលដែលវាដើរស៊ីលើវាលស្មៅ វាលស្មៅត្រូវតែមានវិធានការការពារ:

- មិនត្រូវលែងឱ្យស៊ីលើវាលស្មៅដែលមានចៃច្រើន
- ត្រួតពិនិត្យ និងថែរក្សាវាលស្មៅ

ការការពារសំរេចបានជោគជ័យលុះណាតែមានការចូលរួមទាំងអស់គ្នាពីអ្នកចិញ្ចឹមពពែ។ ពពែត្រូវត្រួតពិនិត្យម្តងមួយៗឱ្យបានទៀងទាត់ ត្រូវឃ្លាំមើលហ្វូងពពែទាំងមូលដោយប្រុងប្រយ័ត្ន។

បើរកឃើញពពែដែលមានចៃត្រូវតែ:

- បំបែកវាចេញពីហ្វូង

- ព្យាបាលវាជាបន្ទាន់ ដើម្បីកុំឱ្យឆ្លងដល់ហ្វូងសត្វទាំងមូល
- ប្រើសាប៊ូដុសលាងវា
- ពពែដែលមានរោមវែងផ្តល់លក្ខណៈងាយស្រួលដល់ចៃក្នុងការបន្តពូជ

កាត់រោមវាឱ្យខ្លីដែលងាយស្រួលក្នុងការត្រួតពិនិត្យ និងកំចាត់ប៉ារ៉ាស៊ីតខាងក្រៅ។ ការព្យាបាលត្រូវធ្វើឡើងវិញដដែលៗ រហូតទាល់តែប៉ារ៉ាស៊ីតត្រូវបានកំចាត់។ ការព្យាបាលតែមួយដង អាចពុំបានជោគជ័យ ប្រសិនបើការព្យាបាលប្រព្រឹត្តទៅជាច្រើនដងហើយមិនបានជោគជ័យ អ្នកត្រូវហៅពេទ្យសត្វ។

## ១១.៤ ប៉ារ៉ាស៊ីតខាងក្នុង

ប៉ារ៉ាស៊ីត គឺជាសត្វល្អិត ដែលរស់នៅខាងក្នុងខ្លួនរបស់ពពែ ភាគច្រើនក្នុងក្រពះ ពោះវៀន ហើយខ្លះរស់នៅក្នុងសួត ថ្លើម និងក្នុងសរីរាង្គដទៃទៀត។ ព្រូន និងប៉ារ៉ាស៊ីតដទៃទៀតអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុខភាពពពែ។ ក្នុងខ្លួនពពែអាចមានព្រូនច្រើនប្រភេទ ព្រូនមូល ព្រូនសំប៉ែត ព្រូនក្នុងសួត។ ពពែមិនធានាទប់ទល់នឹងព្រូនទេ ជាពិសេសគ្រោះថ្នាក់ខ្លាំងចំពោះកូនពពែ និងពពែជំទង់។

ព្រូនផលិតកូនច្រើន ហើយពងរបស់វាមានគ្រប់ទីកន្លែង នៅកន្លែងចិញ្ចឹមគោ លើវាលស្មៅ ។ល។ មួយផ្នែកវដ្តជីវិតរបស់ព្រូនប្រព្រឹត្តទៅនៅក្រៅខ្លួនរបស់សត្វ ពងព្រូនចូលទៅក្នុងពោះសត្វ តាមចំណី ទឹក រួចលូតលាស់បង្កកំណើតនៅក្នុងខ្លួនសត្វ។ ដោយគ្មានបទពិសោធន៍ និងគ្មានការការពារត្រឹមត្រូវ ហ្វូងពពែទាំងមូលនឹងកើតព្រូន ដែលបណ្តាលឱ្យខាតបង់ថវិកាយ៉ាងច្រើនចំពោះអ្នកចិញ្ចឹមពពែ។

ព្រូនច្រើននៅក្នុងខ្លួនសត្វបណ្តាលឱ្យគ្រោះថ្នាក់ធ្ងន់ និងខូចសុខភាពៈ

**រោគសញ្ញា:**

- បាត់បង់ការឃ្លានចំណី ស្រកទំងន់
- ក្អក (ព្រូនក្នុងសួត) មានភាពខ្សោយ
- រោមគ្រើម ហើយបះ
- ឈាមមិនគ្រប់គ្រាន់ (anaemia)
- រោទីពួតិច
- រាគ ចុះស្គមខ្លាំង ហើយងាប់

## ការការពារ និងព្យាបាលប៉ារ៉ាស៊ីតខាងក្នុង

ការការពារមិនឱ្យមានព្រូន និងមិនឱ្យមានប៉ារ៉ាស៊ីតដ៏ទៃទៀតៈ

- ទ្រុងពពែ ស្នូក និងចំណីដាច់ខាតត្រូវតែស្អាត
- ត្រូវប្រើថ្នាំទំលាក់ព្រូនចំពោះហ្វូងសត្វទាំងមូលរាល់ ៣ ខែម្តង

**ទំលាក់ព្រូនៈ**

មានថ្នាំជាច្រើនប្រភេទដែលប្រើបានជោគជ័យសំរាប់ទំលាក់ព្រូន និងប៉ារ៉ាស៊ីតផ្សេងៗ។

វិធានការនៃការទំលាក់ព្រូនៈ

- ពិនិត្យមើលពេលផុតកំណត់របស់ថ្នាំ
- ប្រើថ្នាំឱ្យបានត្រឹមត្រូវស្របទៅនឹងទំងន់របស់សត្វ
- ទំលាក់ព្រូនហ្វូងពពែទាំងមូល
- ប្តូរថ្នាំទំលាក់ព្រូនបន្ទាប់ពីប្រើជាច្រើនដងមកដើម្បីជៀសវាងការស៊ាំថ្នាំរបស់មេរោគ
- ការទំលាក់ព្រូនមិនធ្វើឱ្យប៉ះពាល់ដល់ពពែធំ មេពពែបំបៅកូន និងកូនរបស់វាទេ
- ការទំលាក់ព្រូនចាំបាច់ណាស់បន្ទាប់ពីការចាប់ផ្តើមនៃរដូវភ្លៀងមក

  អ្នកមិនត្រូវផឹកទឹកដោះពពែដែលបញ្ច្រុកថ្នាំរួចបាន ២៤ ម៉ោង។

### ១១.៥ ជំងឺកុកស៊ីដ្យូស៊ីស (Coccidiosis)

កុកស៊ីដ្យូស៊ីស ជាជំងឺធ្ងន់ធ្ងរមួយ។ ជំងឺនេះកើតមានឡើងនៅក្នុងហ្វូងសត្វដោយសារការគ្រប់គ្រងមិនបានល្អ សំខាន់បំផុតគឺទ្រុងពពែ និងលក្ខខ័ណ្ឌនៃការរស់នៅកខ្វក់ គួបផ្សំនឹងការធ្វេសប្រហែសក្នុងការផ្តល់ចំណី។ ជាពិសេសកូនពពែ ពពែជំទង់ និងសត្វដែលខ្សោយមានគ្រោះថ្នាក់ខ្ពស់។ ការឆ្លងមេរោគនិងជំងឺផ្សេងៗអាចធ្វើឱ្យសត្វងាប់ច្រើន និងបណ្តាលឱ្យខាតបង់ថវិកាខ្ពស់។

**មូលហេតុៈ**

បណ្តាលមកពីមេរោគ កុកស៊ីដ្យា (Coccidia) ច្រើន គួបផ្សំជាមួយ

- ការធ្វេសប្រហែស និងការថែទាំគ្មានអនាម័យ (ទ្រុង និងការផ្តល់ចំណី)
- លក្ខខ័ណ្ឌនៃការរស់នៅ ចុះញ្ញថប់ ហត់នឿយ (stress) ដូចជា
  - បន្ទាប់ពីបង្កើតកូន បន្ទាប់ពីផ្តាច់ដោះ បន្ទាប់ពីប្តូរអាកាសធាតុ ក្រោយពីការដឹកជញ្ជូន

○ បន្ទាប់ពីការប្តូរចំណីភ្លាមៗ និងការគ្រប់គ្រង

មេរោគ Coccidia រស់នៅក្នុងពោះវៀនរបស់សត្វ ពពែដែលឆ្លងជំងឺនេះមានភាគតិចតួច ហើយប៉ុន្មានថ្ងៃក្រោយមកអាចបាត់ទៅវិញ។ នៅក្នុងជីវិតមួយពពែស៊ាំទៅនឹងមេរោគ ហើយវាអាចទ្រទ្រង់ទៅនឹងការឆ្លងមេរោគនេះ។

**រោគសញ្ញា:**

- បាត់បង់ការឃ្លានចំណី
- រោមឡើងគ្រើម ហើយស្រកទំងន់
- ភាគពិណ ក្រហម-ត្នោត
- ធ្វើឱ្យពពែងាប់

**ការការពារ:**

ការការពារដែលមានប្រសិទ្ធិភាព:

- ត្រូវមានអនាម័យ និងស្អាតជានិច្ច
- គ្រប់គ្រងឱ្យបានត្រឹមត្រូវ
- ទ្រុងត្រូវស្អាតជានិច្ច
- ការផ្តល់ចំណីត្រូវតែស្អាត

កូនពពែដែលទើបឆ្លងជំងឺនេះព្យាបាលជាមួយ ស៊ុលហ្វាតឌីមីឌីន (Sulphadimidine):

| អាយុ | ការប្រើថ្នាំ |
|---|---|
| ១ ខែ | ១ គ្រាប់/ថ្ងៃ ព្យាបាល ៣ ថ្ងៃ |
| ៣ ខែ | ១ គ្រាប់/ថ្ងៃ ព្យាបាល ៣ ថ្ងៃ |
| ៥ ខែ | ២ គ្រាប់/ថ្ងៃ ព្យាបាល ៣ ថ្ងៃ |

ការព្យាបាលបែបនេះមានតំលៃថោក ហើយមានប្រសិទ្ធិភាព។

**ការព្យាបាល:** ក្នុងករណីភាគច្រើនដងត្រូវហៅពេទ្យសត្វជាបន្ទាន់។

### ១១.៦ ជំងឺខ្វិន (goat paralysis)

**មូលហេតុ:**

ជំងឺខ្វិនពាំពេបណ្ដាលមកពីដង្កូវជ្រៀតចូលក្នុងខ្លួនរបស់វា ដែលពីធម្មជាតិគេរកឃើញកើតមានឡើងចំពោះសត្វគោ។ វាឆ្លងតាមមូសដែលចំលងចូលទៅក្នុងប្រព័ន្ធសរសៃឈាមរបស់ពពែ។ ជំងឺនេះអាចបណ្ដាលឱ្យខាតបង់ថវិកាខ្ពស់។

**រោគសញ្ញា:**

- ជើងខាងក្រោយមានភាពខ្សោយ
- ដំណើរមិនត្រង់ មានសភាពបីដូចអ្នកស្រវឹងស្រា
- ប្រស្រីភ្នែកធ្វើចលនាដោយគ្មានការបញ្ជា
- ពពែខ្វិនមួយផ្នែក ឬខ្វិនទាំងស្រុង។

**វិធានការការពារ:**

- ទំលាក់ព្រូនគោ
- ថែទាំពពែដោយបំបែកចេញពីគោ
  - ◆ ជ្រើសរើសកន្លែងសមស្របសំរាប់ទ្រុងពពែ ដាក់ដាច់ដោយឡែកពីគោ និងឆ្ងាយពីកន្លែងសំបូរមូស
  - ◆ ជៀសវាងការលែងឱ្យស៊ីលើវាលស្មៅជាមួយហ្វូងគោ
- ការពារមូស:
  - ◆ បាញ់ថ្នាំសំលាប់មូស បាញ់ទៅលើប្រភពដែលកើតមូស និងបាញ់ក្នុងទ្រុងពពែ
  - ◆ ចិញ្ចឹមត្រីក្នុងស្រះ។

**ការព្យាបាល:**

- ពុំមានថ្នាំសំរាប់ព្យាបាលសត្វដែលកើតជំងឺនេះក្នុងដំណាក់កាលចុងក្រោយ
- ត្រូវហៅពេទ្យសត្វជួយ។

### ១១.៧ ជំងឺសួត (pneumonia)

ជំងឺសួតជាជំងឺមួយដ៏ធ្ងន់ធ្ងរ ជាពិសេសមានភាពគ្រោះថ្នាក់សំរាប់ពពែនៅក្មេង។ ពិសេសទៅទៀតចំពោះអាកាសធាតុត្រជាក់ហើយសើម នៅពេលដែលពពែទទួលនូវភាពត្រជាក់នេះដែលបង្កឱ្យមានភាពគ្រោះថ្នាក់ខ្លាំងចំពោះជំងឺសួត។

ការការពារដ៏មានប្រសិទ្ធិភាពបំផុត គឺធ្វើទ្រុងឱ្យបានល្អ គ្រប់គ្រងឱ្យបានត្រឹមត្រូវ និងការផ្តល់ចំណីបានល្អ។

ជំងឺសួតកើតមានឡើងជាញឹកញាប់:

- ចំពោះសត្វដែលខ្សោយ
- ចំពោះសត្វដែលនឿយហត់ ឬធុញថប់ (stress conditions) ដូចជា
    - ◆ បន្ទាប់ពីកើតកូនរួច
    - ◆ បន្ទាប់ពីការប្តូរអាកាសធាតុយ៉ាងរហ័ស
    - ◆ បន្ទាប់ពីការដឹកជញ្ជូនសត្វ
    - ◆ បន្ទាប់ពីការប្តូរចំណីភ្លាមៗ និងការគ្រប់គ្រង។

**មូលហេតុ:**

ជំងឺសួតអាចបណ្តាលមកពីកត្តាជាច្រើន:

- វីរុស (virus) ឬបាក់តេរី (bacteria)
- ប៉ារ៉ាស៊ីត (lung worms ព្រូនសួត) ឬផ្សិត។

**រោគសញ្ញា:**

- បាត់បង់ការឃ្លានចំណី
- អាការៈខាងក្រៅមានភាពធុញទ្រាន់
- ក្អក
- ពិបាកក្នុងការដកដង្ហើម
- គ្រុនក្តៅ។

**ការការពារ:**

- ធ្វើទ្រុងពពែឱ្យបានល្អ ទ្រុងត្រូវស្អាត ស្ងួត និងមានខ្យល់ចេញចូលល្អ
- ផ្តល់ចំណីពពែឱ្យបានល្អ
- ទំលាក់ព្រូនឱ្យបានទៀងទាត់រាល់ ៣ ខែម្តង
- ហ្វូងពពែចិញ្ចឹមក្នុងចំនួនដែលអ្នកអាចថែរក្សាបានហ្មត់ចត់
- ជៀសវាងការចិញ្ចឹមដាក់ពពែច្រើនជ្រុលក្នុងទ្រុងតែមួយ។

**ការពារពពែពីភាពត្រជាក់:**

- មិនត្រូវលែងពពែឱ្យស៊ីលើវាលស្មៅនៅពេលភ្លៀង និងខ្យល់
- ធ្វើសំបុកឱ្យកូនពពែ
- ប្រក់ទ្រុងពពែឱ្យបានត្រឹមត្រូវដើម្បីការពារភាពត្រជាក់ ខ្យល់ និងភ្លៀង ។

**ការព្យាបាលៈ**

- ពពែឈឺត្រូវបំបែកចេញពីហ្វូង និងផ្តល់កំដៅឱ្យវា
- ផ្តល់ចំណីឱ្យបានល្អ
- ត្រូវការការណែនាំ និងជំនួយពីពេទ្យសត្វ ។

### ១១.៨ ជំងឺរលាកស្បែក (Contagious Pustular Dermatitis)

ជាជំងឺមួយដែលឆ្លងរាលដាលនៅត្រង់មាត់ និងច្រមុះ ហើយដែលច្រើនកើតចំពោះពពែ និងចៀម ។ បើជំងឺនេះកើតចំពោះពពែណាមួយ នោះហ្វូងពពែទាំងមូលនឹងមានគ្រោះថ្នាក់ ។

**រោគសញ្ញាៈ**

- ដំបៅស្ងួត ពិណគ្នោត នៅជុំវិញមាត់ច្រមុះ (មានក្រមរ និងធ្វើឱ្យសត្វឈឺ)
- មានស្នាមប្រេះនៅលើបបូរមាត់ លើច្រមុះ និងលើអញ្ចាញធ្មេញ ដែលបណ្តាលឱ្យសត្វមានការឈឺចាប់ នៅពេលវាបៅ ឬស៊ីចំណី
- សត្វបាត់បង់ការឃ្លានចំណី និងមិនព្រមស៊ីចំណី ។

**ការការពារៈ**

- បំបែកសត្វដែលឆ្លងជំងឺនេះចេញពីហ្វូង
- ចំពោះតំបន់ដែលកើតជំងឺនេះញឹកញាប់ ត្រូវចាក់វ៉ាក់សាំងកូនពពែដែលមានអាយុពី ៦-៨ សប្តាហ៍ ត្រូវចាក់វ៉ាក់សាំងឡើងវិញបន្ទាប់ពី ២ ឆ្នាំ

ចំពោះការចាក់វ៉ាក់សាំង គួរតែមានការផ្តល់យោបល់ពីពេទ្យសត្វ និងថ្នាំវ៉ាក់សាំងគួរតែរៀបចំពីពេទ្យសត្វ ។

**ការព្យាបាលៈ**

- ផ្តល់ចំណីទន់ និងមានឱជារសដល់សត្វ
- លាបដំបៅដោយប្រើល្បាយសាច់ជូរវាវ (alum ៥%)
- កេះក្រមរដំបៅចេញដោយប្រើសំឡី និងស្បៃស្អាត ហើយប្រើថ្នាំលាបដំបៅ (Gentian Violet)
- ក្នុងករណីចាំបាច់ត្រូវហៅបសុពេទ្យជាបន្ទាន់ ។

## ១១.៩ ជំងឺហើមពោះ (Bloat)

ជំងឺនេះបង្កឡើងដោយការកើនឡើងនូវឧស្ម័នក្នុងក្រពះ (rumen)។ ក្រពះរបស់សត្វពពែឡើងប៉ោង ឬហើម។

**មូលហេតុ:**

- ◆ ការផ្តល់ចំណីខុស (របបចំណីពុំមានតុល្យភាព)
- ◆ កំរិតនៃការរំលាយអាហារខ្ពស់ ចំណីសំបូរប្រូតេអ៊ីនខ្ពស់ ដូចជា ពពួករុក្ខជាតិកូរ ស្មៅខ្ចី ស្លឹករុក្ខជាតិខ្ចី ។ល។
- ◆ ដំណើរការពីក្រពះទៅបំពង់កត្រូវស្ទះ
- ◆ បណ្តាលឱ្យកើតជំងឺផ្សេងៗ ទៀត។

**រោគសញ្ញា:**

- សត្វមានការឈឺចុកចាប់
- ពិបាកក្នុងការដកដង្ហើម
- ក្រពះឡើងហើមធំដែលអាចដឹងបាននៅផ្នែកខាងឆ្វេង
- បើយើងវាយផ្នែកខាងឆ្វេង (ត្រង់កន្លែងដែលក្រពះឡើងធំ) វានឹងឮសំឡេងដូចស្គរ។

**ការការពារ:**

- ប្រតិបត្តិតាមក្បួនខ្នាតនៃការផ្តល់ចំណីឱ្យបានត្រឹមត្រូវ (ទាំងក្នុងទ្រុង និងការឱ្យស៊ីលើវាលស្មៅ)
- របបចំណីត្រូវផ្តល់ឱ្យមានតុល្យភាព។

**ការព្យាបាល:** ការហើមពោះត្រូវការប្រុងប្រយ័ត្នជាបន្ទាន់:

- ◆ បញ្ឈប់ការផ្តល់ចំណីដល់សត្វ
- ◆ ត្រូវឱ្យសត្វឈរនៅកន្លែងរាងជំរាល ជើងមុខខ្ពស់ជាងជើងខាងក្រោយ រួចសង្កត់ថ្នមៗត្រង់កន្លែងហើមពោះ។ ទាំងនេះអាចធ្វើឱ្យសត្វបញ្ចេញឧស្ម័នខ្លះពីពោះរបស់វា។
- ◆ រឹតប្រេងលើពោះរបស់វាដោយថ្នមៗ
- ◆ ក្នុងករណីចាំបាច់ត្រូវហៅបសុពេទ្យជាបន្ទាន់។

## ១១.១០ ជំងឺរលាកដោះ (mastitis)

ជាជំងឺរលាកកន្សោមដោះ វាអាចធ្វើឱ្យខូចជាលិកាផលិតទឹកដោះ (ទាំងសងខាង ឬតែម្ខាង)។

**មូលហេតុ:**

បណ្តាលមកពីប្រភេទបាក់តេរីផ្សេងៗរួមផ្សំជាមួយការថែទាំគ្មានអនាម័យ ដូចជា ទ្រុងកខ្វក់ និងការយកទឹកដោះមិនបានសំអាតត្រឹមត្រូវ ឬបណ្តាលមកពីការរឹតយកទឹកដោះខ្លាំងពេក។

**រោគសញ្ញា:**

- ទឹកដោះថយចុះ
- ទឹកដោះមិនខាប់ហើយរាវ
- ទឹកដោះមានបំណែកដុំតូចៗ និងមានលាយខ្ទុះ
- ទឹកដោះប្តូរពណ៌ (ពណ៌លឿង ឬក្រហម)
- កន្សោមដោះឡើងហើមធំ ក្តៅ និងពណ៌ក្រហម។

**ការការពារ:**

- ការគ្រប់គ្រងបានល្អ និងមានភាពស្អាតជានិច្ច
- លាងដៃឱ្យស្អាតមុននឹងច្របាច់យកទឹកដោះ
- លាងកន្សោមដោះឱ្យបានស្អាតមុននឹងច្របាច់យកទឹកដោះ។

**ការព្យាបាល:**

ក្នុងពេលកើតជំងឺនេះភ្លាមយើងអាចព្យាបាលបានដោយជោគជ័យ ករណីពិសេសត្រូវហៅពេទ្យសត្វភូមិជាបន្ទាន់។

## ១១.១១ ជំងឺអុតក្តាម

ជាជំងឺឆ្លងរាតត្បាតមួយដែលកើតមានឡើងចំពោះ គោ ក្របី ពពែ ។ល។ ជំងឺនេះច្រើនកើតក្នុងរដូវភ្លៀង។ បើពពែមួយកើតនោះវានឹងឆ្លងរាលដាលពេញក្នុងហ្វូង។

**រោគសញ្ញា:**

- សត្វក្តៅខ្លួន សីតុណ្ហភាពឡើងខ្ពស់ ៤០-៤១ អង្សាសេ
- មានពងបែក ដំបៅក្នុងមាត់ លើអញ្ចាញធ្មេញ និងត្រង់ដោះ

- មានដំបៅនៅចន្លោះក្រចកជើង ហើយមានហូរទឹករងៃ ឬមានខ្ទុះ

  ករណីធ្ងន់ធ្ងរអាចរបកក្រចកជើង

- ហើមអណ្តាត ធ្វើឱ្យសត្វពិបាកផឹកទឹក និងស៊ីចំណី
- ហៀរទឹកមាត់អន្ទាយ
- ជួនកាលសត្វអាចរាគ
- ចំពោះមេផើមអាចធ្វើឱ្យវារលូតកូន ។

**ការព្យាបាលៈ**

មានវិធីព្យាបាលមួយចំនួនដោយប្រើថ្នាំចាក់ និងការប្រើឱសថបូរាណលាបទៅលើមុខដំបៅដែលបង្កឡើងដោយជំងឺនេះ ។

ឱសថបូរាណដែលប្រជាកសិករយើងធ្លាប់ប្រើមានៈ

- ថ្នាំជក់ ដែលជាប្រភេទថ្នាំខ្លាំង
- កំបោរ ដែលចាស់ៗពិសាជាមួយស្លាម្លូ
- ខ្លាញ់ត្រី និងធ្យូងបាតខ្ទះ ។

**របៀបផ្សំៈ**

បុកលាយសារធាតុខាងលើចូលគ្នា រួចយកជូតកន្លែងដំបៅ បន្ទាប់មកយកខ្លាញ់ត្រីលាយជាមួយធ្យូងបាតខ្ទះ កូរវាឱ្យសព្វយកទៅជូតលើដំបៅដើម្បីកុំឱ្យរុយរោម ព្យាបាលរយៈពេល ៥ ថ្ងៃ ក្នុងករណីធ្ងន់ធ្ងរអាចប្រើពេល ១០ ថ្ងៃ ។

គេអាចយកសាច់ដូរដុសលាងមុខដំបៅ ឬអាចប្រើក្រូចឆ្មា គេអាចប្រើទឹកក្រេស៊ីល ៥% សំរាប់លាងក្រចកដែលដំបៅ ។ ចំពោះថ្នាំចាក់មានដូចជា អំពីស៊ីលីន (Ampiciline) ឬអាណាសាំង (Anagine) ចាក់សាច់ដុំ ១ cc សំរាប់ ១០ គីឡូក្រាម សត្វរស់ ក្នុង ១ ថ្ងៃចាក់២ដង ពេលព្រឹកម្តង និងពេលល្ងាចម្តង ។

អ្នកត្រូវបំប៉នសត្វឱ្យបានល្អ និងផ្តល់ចំណីទន់ៗ ដើម្បីឱ្យវាងាយស្រួលស៊ី ។ ជៀសវាងកុំឱ្យសត្វត្រាំទឹក ឱ្យវានៅកន្លែងស្ងួត យកល្អត្រូវក្រាលចំបើងពីក្រោមឱ្យសត្វ ចំណី និងទឹកដែលផ្តល់ឱ្យសត្វត្រូវស្អាតជានិច្ច ។

## ១១.១២ ជំងឺសារទឹក

ជាជំងឺឆ្លងដ៏សាហាវមួយ និងច្រើនកើតក្នុងរដូវភ្លៀង កសិករមានការភ័យខ្លាចខ្លាំងចំពោះជំងឺនេះ ។ បើជំងឺនេះកើតមានឡើង នោះវាបណ្តាលឱ្យសត្វងាប់ច្រើន និងធ្វើឱ្យកសិករខាតបង់ខ្ពស់ ។

**មូលហេតុ:**

- ការផ្តល់ចំណីមិនគ្រប់គ្រាន់
- បរិយាកាសមិនល្អ និងល័ក្ខខ័ណ្ឌនៃការរស់នៅធ្វើឱ្យវាធុញថប់ (Stress)
- បង្ករឡើងដោយបាក់តេរី

**រោគសញ្ញា:**

- សត្វមិនចង់ស៊ីចំណី
- សត្វមិនចង់កំរើក ពុំសូវធ្វើចលនា
- សត្វគ្រុនក្តៅ សីតុណ្ហភាពឡើងខ្ពស់ ៤០-៤១ អង្សាសេ
- ច្រមុះស្ងួត
- សត្វហៀរទឹកមាត់ និងសំបោរ
- ពេលខ្លះអណ្តាតរបស់សត្វលៀនចេញមកក្រៅ
- សត្វហើមក ហើមទ្រូង ជើងមុខ និងហើមត្រគាក
- នៅត្រង់កន្លែងហើមមានសភាពទន់
- រាគមានលាយឈាម ។

**ការព្យាបាល:**

- គេអាចប្រើថ្នាំចាក់ដូចជា ស្ត្រីបតូមីស៊ីន (Streptomycine) ស៊ុលហ្វាឌីមីឌីន (Sulfadimidine) និង អាត្រូពីន (Atropine) ។
- កសិករខ្លះគាត់នៅប្រើឱសថបូរាណសំរាប់ព្យាបាលជំងឺសារទឹក ដូចជា:

ថ្នាំខ្លាំង និងចេកជ្វា បុកបញ្ចូលគ្នាលាយជាមួយទឹក រួចពូតយកទឹកបញ្ច្រុកសត្វ ១ថ្ងៃ២ដង ។

## ១១.១៣ ជំងឺបុស្គខ្យល់

ជាជំងឺឆ្លងដ៏កាចសាហាវមួយហើយច្រើនកើតមានឡើងចំពោះសត្វ គោ ក្របី ពពែ ជ្រូក ។ល។ លក្ខណៈពិសេសរបស់ជំងឺនេះគឺគ្រុនក្តៅ ហើមនៅក្នុងសាច់ដែលបណ្តាលមកពីហ្គាស សត្វដែលកើតជំងឺនេះអាចងាប់យ៉ាងឆាប់រហ័ស ។

**រោគសញ្ញាៈ**

- សត្វមិនចង់ធ្វើចលនា
- ពិបាកដកដង្ហើម
- សត្វមិនចង់ស៊ីចំណី និងមិនចង់នៅក្នុងហ្វូង
- សីតុណ្ហភាពក្នុងខ្លួនសត្វឡើងខ្ពស់ ៤០-៤១ អង្សាសេ
- មានហើមពកនៅត្រង់ម្តុំភ្លៅ ត្រគាក សងខាងស្មា និងទ្រូង កន្លែងហើមប៉ោង បើយើងស្ទាបក្តៅ និងធ្វើឱ្យសត្វឈឺចុកចាប់
- ជំងឺនេះធ្វើឱ្យសត្វងាប់យ៉ាងរហ័សពី ១-២ ថ្ងៃ

**ការព្យាបាលៈ**

◆ គេអាចប្រើថ្នាំចាក់ដូចជា ប៉េនីស៊ីលីន (Penicillin) អ៊ិចធេនស៊ីលីន

◆ ការព្យាបាលតាមបែបសាមញ្ញៈ នៅពេលបួសឡើងទុំក្រហមគេយកកាំបិតមុតវះពីលើ រួចច្របាច់ខ្ទុះឱ្យអស់ បន្ទាប់មកគេយកខ្លាញ់ត្រីលាយជាមួយធ្យូងបាតខ្ទះ មកលាបពីលើមុខរបួស ។

កសិករខ្លះយក វល្លិកំបោរ ដើមអង្គ្រង សត្វជន្លេន បុកលាយជាមួយទឹក រួចបញ្ចុកសត្វក្នុង១ថ្ងៃ ៣ដង ក្នុង១ដង ៣បំពង់ឫស្សីតូច ។

**តារាងទី ៣: ជំងឺសំខាន់ៗ**

| ជំងឺ | កើតច្រើនចំពោះពពែមានអាយុ | មូលហេតុ | កត្តាដែលនាំឱ្យកើត ជំងឺ | រោគសញ្ញា | ការការពារ និងព្យាបាល |
|---|---|---|---|---|---|
| ព្រូន | កូនពពែ និងពពែជំទង់ | ព្រូនមូល<br>ព្រូនសំប៉ែត<br>ព្រូនថ្លើម | ភាពកខ្វក់, ទ្រុងមិនល្អ, ចំណីមិនគ្រប់គ្រាន់, ការគ្រប់គ្រង | ស្រកទំងន់, ចុះស្គម, ក្អក, រីមគ្រើម, ឈាមមិនគ្រប់គ្រាន់, រាគ | - ធ្វើអនាម័យឱ្យបានល្អ<br>- ទំលាក់ព្រូនបានទៀងទាត់ |

| | | | | | |
|---|---|---|---|---|---|
| | | | ធ្វេសប្រហែស | | |
| **កុកស៊ីដ្យូស៊ីស (Cocci - diosis)** | កូនពពែ និងពពែជំទង់ | ប៉ារ៉ាស៊ីត កុកស៊ីដ្យា (Coccidia) | ភាពកខ្វក់, ទ្រុងមិនល្អ, ចំណីមិនគ្រប់គ្រាន់, ការគ្រប់គ្រងធ្វេសប្រហែស | ស្រកទំងន់, ចុះស្គម, ក្អក, រើមគ្រើម, ឈាមមិនគ្រប់គ្រាន់, រាគពិណក្រហម | - ធ្វើអនាម័យឱ្យបានល្អ<br>- ប្រើថ្នាំស៊ុលហ្វា<br>- បើរាគច្រើនដងហៅបសុពេទ្យ |
| **ប៉ារ៉ាស៊ីតខាងក្រៅ** | ចំពោះសត្វទាំងអស់ក្នុងហ្វូង | ចៃ ចៃតឹកកែ | វាលស្មៅសំបូរចៃ, ខ្វះការថែរក្សា | មានដូចជាដំបៅលើស្បែក, ជ្រុះរោម, រមាស់ | - ត្រួតពិនិត្យពពែឱ្យបានទៀងទាត់<br>- ដុសលាង, បាញ់ថ្នាំសំលាប់សត្វល្អិត |
| **ជំងឺសួត (Pneu-monia)** | ពពែក្មេង | វីរុស, បាក់តេរី, ប៉ារ៉ាស៊ីត, ផ្សិត | ទ្រុងមិនល្អ, ត្រជាក់, ខ្សោយ និងស្ត្រេស | ក្អក, ហៀរសំបោរ, គ្រុនក្តៅ | - ត្រូវស្អាតជានិច្ច, ទ្រុងស្ងួត<br>- ការពារពីភាពត្រជាក់<br>- ទំលាក់ព្រូនទៀងទាត់, ករណីចាំបាច់ហៅបសុពេទ្យ |
| **ជំងឺខ្ទិន (goat** | ចំពោះសត្វទាំងអស់ក្នុងហ្វូង | ប៉ារ៉ាស៊ីតឆ្លងពីសត្វគោ | មូស, ស៊ីលើវាលស្មៅជាមួយគោ | ពិបាកដើរ, ប្រស្រីភ្នែក | - ឃ្វាលពពែឱ្យឆ្ងាយពីគោ |

| | | | | | |
|---|---|---|---|---|---|
| paralysis) | | | | កំរើកចុះឡើង, ខ្វិន | - ត្រួតពិនិត្យ មូស<br>- វិធីព្យាបាល (ពេទ្យសត្វ) |
| ជំងឺរលាកស្បែក (Contagious Pustular Dermatitis) | ចំពោះសត្វទាំងអស់ក្នុងហ្វូង | វ៉ារុស | - | បាត់បង់ការឃ្លានចំណី, ក្រមរក្រៀមពិណាត្នោត ជុំវិញមាត់ ច្រមុះ | - ចាក់វ៉ាក់សាំង<br>- បំបែកសត្វឈឺចេញពីហ្វូង<br>- ថែរក្សាដំបៅ |
| ក្រចកពិណក្រហម | ចំពោះសត្វទាំងអស់ក្នុងហ្វូង | វាលស្មៅសើម, ទ្រុងកខ្វក់, មិនតំរឹមក្រចក | ការធ្វេសប្រហែស | ក្រចកហើមធំ, ដើរមិនរួច | - មិនត្រូវឱ្យស៊ីលើវាលស្មៅសើម<br>- សំអាតទ្រុង, ទ្រុងស្ងួត<br>- តំរឹមក្រចកឱ្យបានទៀងទាត់<br>- ឧស្សាហ៍លាងក្រចក |
| ជំងឺហើមពោះ (Bloat) | ពពែក្មេង និងពពែពេញវ័យ | ការផ្តល់ចំណីពុំមានតុល្យភាព, ពពួករុក្ខជាតិក្បួរច្រើនពេក និងស្មៅខ្ចី | ការធ្វេសប្រហែស | ពោះឡើងហើមធំ, ធ្វើឱ្យសត្វឈឺចុកចាប់ | - ការផ្តល់ចំណីត្រូវត្រួតពិនិត្យត្រឹមត្រូវ<br>- ករណីចាំបាច់ហៅពេទ្យសត្វ |
| ជំងឺរលាកដោះ | ពពែកំពុងបញ្ចេញ | បាក់តេរី | ទ្រុងគ្មានអនាម័យ, | កន្សោមដោះហើមធំ, | - សំអាតទ្រុង<br>- រាល់ពេល |

| | | | | | |
|---|---|---|---|---|---|
| (mastitis) | ទឹកដោះ | | ការរឹតយកទឹកដោះមិនសំអាតត្រឹមត្រូវ | ទឹកដោះមានលាយឈាមដុំឈាម និងកករ | យកទឹកដោះត្រូវសំអាត -ករណីចាំបាច់ហៅបសុពេទ្យ |
| **តេតាណុស** **(Tetanus)** | កូនពពែ | បាក់តេរី | ការធ្វេសប្រហែស | - | - សំលាប់មេរោគលើទងផ្ចិត និងព្យាបាលវាជាបន្ទាន់ |

ម.ព.ឯ.ក AIDOC
Code: ______
Date: ______
Donated by: ______




**អាស័យដ្ឋានទំនាក់ទំនង**

ផ្ទះលេខ ៣៩ ផ្លូវ ៥២៨ សង្កាត់បឹងកក់ ១
ខ័ណ្ឌ ទួលគោក  រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ១១១៨
ទូរស័ព្ទ : ៨៥៥_២៣ _ ៨៨០ ៩១៦
ទូរសារ : ៨៥៥_២៣ _ ៨៨៥ ១៤៦



**Address**

CEDAC, # 39, Street 528
Phnom Penh, Cambodia
P.O.Box: 1118
Tel: 855 23 880 916
Fax: 855 23 885 416
email : cedac@camnet.com.kh,
cedacrc@camnet.com.kh